include.innovate.influence.




# សន្ទានុក្រម

កួយ

ខ្មែរ

អង់គ្លេស

សន្ទានុក្រមនេះបោះពុម្ពដោយអូ ភី ខេ ស៊ី















# មាតិកា


១ សេចក្តីថ្លែងអំណរគុណ

២ អំពីសៀវភៅអក្ខរក្រមកួយ

៣ ផែនទីបង្ហាញពីទីតាំងជនជាតិកួយរស់នៅក្នុងប្រទេសកម្ពុជា

៤ ព័ត៌មានជនជាតិកួយ

៥ ប្រវត្តិពាក់ព័ន្ធជនជាតិកួយ និង ភូមិសាស្ត្រពីបុរាណ និងបច្ចុប្បន្ន

៦ ពហុភាសាកួយ និងអត្ថន័យ

៧ ពាក្យភាសាកួយបកប្រែជាភាសាខ្មែរ និង អង់គ្លេស

## ១. សេចក្តីថ្លែងអំណរគុណ

កម្មវិធីចំណេះដឹង និង សហគមន៍ ដែលហៅជាភាសាអង់គ្លេសថា KNOWLEDGE AND COMMUNITY (K&C) នៃអង្គការលើកស្ទួយវប្បធម៌កួយ ដែលហៅកាត់ថា ល.វ.ក ជាភាសាអង់គ្លេសថា ORGANIZATION FOR THE PROMOTION OF KUI CULTURE (OPKC) ឬហៅកាត់ជាភាសាខ្មែរថា អូ.ភី.ខេ.ស៊ី សូមថ្លែងអំណរគុណដល់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងអង្គការលើកស្ទួយវប្បធម៌កួយ ដែលបានរួមចំណែក និងគាំទ្រសកម្មភាពនូវគំនិតផ្តួចផ្តើមនៃកម្មវិធីក្នុងការស្វែងរកដៃគូរគាំទ្រ និងចូលរួមផ្តល់មតិយោបល់សម្រាប់ការបោះពុម្ពសៀវភៅអក្ខរក្រមបីភាសា (កួយ-ខ្មែរ-អង់គ្លេស)នេះឡើង។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់កម្មវិធី**វ៉យ(VOICE)** នៃអង្គការអុកស្វាម(**OXFAM)** ដែលបានគាំទ្រមូលនិធិមកអង្គការលើកស្ទួយវប្បធម៌កួយតាមរយៈគម្រោង " **លើកកម្ពស់ភាសា និងការពង្រឹងភាពអង់អាចសហគមន៍ជនជាតិដើមភាគតិចកួយ**" ចាប់តាំងពីខែមេសាឆ្នាំ២០២២រហូតដល់ខែមេសាឆ្នាំ២០២៤។ លើសពីនេះទៀត សូមថ្លែងអំណរគុណដល់អង្គការ Live and Learn Cambodia តាមរយៈគម្រោង Linking and Learning ដែលបានឧបត្ថម្ភ និងផ្តល់ការកសាងសមត្ថភាពជាច្រើនវគ្គដល់ក្រុមការងារគម្រោង/កម្មវិធីនៃអង្គការលើកស្ទួយវប្បធម៌កួយ។

សូមអរគុណដល់លោក រស់ លីម និងអ្នកស្រី ទេព ទឹម ជាក្រុមប្រឹក្សាយោបល់នៃអង្គកល.វ.ក ដែលបានចូលរួមកំណត់សញ្ញាណអ្នកដែលត្រូវចងក្រងពាក្យកួយ។ សូមអរគុណដល់លោក អ៊ុន វី លោក ហ៊ុត សារី លោក អៀម អោន លោក ផាវ យ៉ន លោក ឃា សុជា លោក ទន់ មាន លោក អុំ មិច លោកស្រី ងួន ហៀង លោកស្រី ហួត ម៉ាលី លោកស្រី ព្រំ ញេប លោកស្រី ស៊ិន បា លោកស្រី ពុត ស៊ីន ។ល។ ជាក្រុមសកម្មគិតគូរសហគមន៍(ATTGs) និងលោក អុំ ប៊ុនថន លោកស្រី នួន សីលួន លោកស្រី ហាវ សុហាង លោកស្រី ភា សុភាព លោកស្រី យីន ម៉ី លោក ពាន សុផាត លោក សឿន ថា ។ល។ ជាក្រុមអប់រំយុវជនពង្រឹងភាសាកួយ(ETTGs) ដែលបានចូលរួមចំណែកក្នុងការផ្តល់ពាក្យ អត្ថន័យ និងខ្លឹមសារភាសាកួយ។ សូមអរគុណចំពោះទឹកចិត្តដ៏ប្រពៃថ្លៃថ្លារបស់អាជ្ញាធរភូមិ អាជ្ញាធរឃុំ និងអាជ្ញាធរប្រពៃណីក្នុងសហគមន៍គោលដៅកម្មវិធី និងគម្រោងមានដូចជាៈ ខេត្តព្រះវិហារ ខេត្តកំពង់ធំ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តឧត្តមានជ័យ ខេត្តបន្ទាយមាជ័យ និង ខេត្តសៀមរាប ដែលបានចូលរួមផ្តល់យោបល់លើពាក្យនៃភាសាកួយ ជាមួយនឹងការផ្តល់ទិន្នន័យ និងស្ថិតិអំពីកួយពីបូរាណ និងបច្ចុប្បន្ន ព្រមទាំងបានអនុញ្ញាត និងផ្តល់ព័ត៌មានលម្អិតអំពីប្រភេទពាក្យកួយតាមតំបន់ ន័យពាក្យ និងគុណតម្លៃពាក្យ។

សូមអរគុណដល់ទីភ្នាក់ងារ និងក្រុមការងារបច្ចេកទេសភូមិអាស៊ីដែលទទួលសេវាកម្មធ្វើអក្ខរក្រមបីភាសា (កួយ-ខ្មែរ-អង់គ្លេស) តាមរយៈការអភិវឌ្ឍន៍គេហៈទំព័រអក្ខរក្រមពហុភាសាកួយ។ ជាមួយគ្នានេះផងដែរ សូមថ្លែងអំណរគុណដល់លោកគ្រូ អ្នកគ្រូក្រុមការងារមន្ទីរវប្បធម៌ខេត្តកំពង់ធំដែលបានចូលរួមផ្តល់យោបល់ គិតគូរ គាំទ្រ និងលើកទឹកចិត្តក្នុងសកម្មភាពលើកស្ទួយភាសាកួយ។

**នាយកកម្មវិធី ខេ.អែន.ស៊ី**

**នាយកប្រតិបត្តិអូ.ភី.ខេ.ស៊ី**

**លោក ហ៊ីង ប៊ុនណាត**

## ២. អំពីសៀវភៅអក្ខរក្រមភាសាកួយ

### បុព្វហេតុ

អង្គការលើកស្ទួយវប្បធម៌កួយ តាមរយៈកម្មវិធីចំណេះដឹងនិងសហគមន៍ បានអនុវត្តគម្រោងស្តីពី "**ការលើកកម្ពស់ភាសាដើមកួយ និងភាពអង់អាចសហគមន៍**" ក្រោមមូលនិធិពី VOICE។ គម្រោងបានសហការជាមួយអាជ្ញាធរ និងយុវជនជាជនជាតិកួយក្នុងខេត្តព្រះវិហារ និងខេត្តកំពង់ធំ ព្រមទាំងខេត្តមួយចំនួនទៀតចាប់ពីខែមេសាឆ្នាំ២០២២ដល់ខែមេសាឆ្នាំ២០២៤។ បញ្ហាដែលបានរកឃើញ អង្គការលើកស្ទួយវប្បធម៌កួយបានចងក្រងក្រុមការងារសហគមន៍កួយបន្តការសិក្សាស្រាវជ្រាវ ចងក្រងភាសារកួយបុរាណ និងពាក្យកួយបច្ចុប្បន្ន។ អក្សរជនជាតិដើមភាគតិចកួយបានបាត់បង់ដោយនៅសល់តែរឿងនិទានតៗគ្នា។ ភាសាកួយត្រូវបានប្រមូលចងក្រងដើម្បីធ្វើជាសៀវភៅ វចនានុក្រម រក្សាទុកតាមអែប គេហទំព័រ និងប្រព័ន្ធសង្គម។ សហគមន៍ជនជាតិដើមភាគតិចកួយដែលស្ថិតក្នុងតំបន់ក្រុមហ៊ុនសម្បទានសេដ្ឋកិច្ច និងសម្បទានរ៉ែ បានបន្លឺសម្លេងរបស់ខ្លួនអំពីការប្រើប្រាស់សិទ្ធិតាមយរៈការនិយាយភាសាដើម អត្តសញ្ញាណត្រូវបានយកចិត្តទុកដាក់ឡើងវិញដោយយុវជន។

### ខ្លឹមសារ

អង្គការលើកស្ទួយវប្បធម៌កួយ (OPKC) បានពង្រឹងការនិយាយភាសាកួយឡើងវិញ ដោយផ្តើមចេញពីជនជាតិកួយខ្លួនឯងតាមរយៈក្រុមប្រពៃណី ក្រុមសហគមន៍ដែលបានចងក្រង និងសកម្មភាពផ្សារភ្ជាប់រវាងចាស់ទុំនិងយុវជន។ សហគមន៍កួយបានទំនាក់ទំនងគ្នាជាភាសាកួយពីតំបន់មួយទៅតំបន់មួយតាមរយៈការផ្ទេរចំណេះដឹង និងទំនាក់ទំនងព័ត៌មានសង្គម។ ក្រុមសកម្មគិតគូរសហគមន៍(ATTGs)ត្រូវបានចងក្រងនៅតាមខេត្ត។ ក្រុមអប់រំយុវជនកួយ(ETTGs) ត្រូវបានចងក្រងឡើងផ្តោតលើសកម្មភាពចូលរួមចងក្រងភាសាកួយ ការរៀនភាសាកួយ និងការបង្រៀនភាសាកួយ។

### គោលបំណង

គម្រោងមានគោលដៅ ដើម្បីលើកកម្ពស់ភាសាជនជាតិដើមភាគតិចកួយ តាមរយៈវចនានុក្រមកម្មវិធីពហុភាសា និងការពង្រឹងភាពអង់អាចសហគមន៍កួយ អមដោយគោលបំណងរួមចំនួនពីរគឺៈ ទីមួយៈបង្កើនចំណេះដឹងពីភាពអង់អាចរបស់សហគមន៍កួយ តាមរយៈការពង្រឹងការភាពអង់អាចដល់សហគមន៍កួយ ក្នុងការកសាងបណ្តាញសកម្មដោយមានក្រុមការងារសហគមន៍កួយធ្វើសកម្មភាពរួមគ្នា។ ទីពីរៈការពង្រឹងពហុភាសាជនជាតិកួយតាមរយៈការផ្សព្វផ្សាយវចនានុក្រមពហុភាសាកួយតាមរយៈការចងក្រងពាក្យថ្មីនិងពាក្យពីបុរាណនិងធ្វើឲ្យមានតាមលំដាប់អក្ខរក្រមដាក់ក្នុងប្រព័ន្ធកម្មវិធីអនឡាញ និងការផ្សព្វផ្សាយវចនានុក្រម និងអក្ខរក្រមក្នុងពត៌មានសង្គមឲ្យកាន់តែមានសម្លេង។

## ៣. ផែនទីសិក្សាបង្ហាញពីទីតាំងខេត្តដែលមានជនជាតិកួយកំពុងរស់នៅក្នុងប្រទេសកម្ពុជា




- ជនជាតិកួយ ជាជនជាតិមួយក្នុងចំណោមជនជាតិដើមផ្សេងៗទៀត មានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមានដើមកំណើតពីដូនតា និងកំពុងតែរស់នៅភាគខាងជើងនៃប្រទេសកម្ពុជា ស្ថិតក្នុងតំបន់នៃខេត្តចំនួនទាំង**០៧គឺ** ខេត្តព្រះវិហារ ខេត្តកំពង់ធំ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តសៀមរាប ខេត្តឧត្តមានជ័យ និងខេត្តបន្ទាយជ័យ។
- នៅក្រោយឆ្នាំ១៩៧៩ ជនជាតិកួយបានទៅរស់នៅតាមបណ្ដាខេត្តផ្សេងៗនៃព្រះរាជាណាចក្រកម្ពុជាក្នុងលក្ខខណ្ឌផ្លាស់ប្ដូរទីលំនៅ ចំណាកស្រុកក្នុងប្រទេស និងតាមគ្រួសារ។

៣.១ ការសិក្សាព័ត៌មានជនជាតិកួយនៅក្នុងខេត្តព្រះវិហារ




ក្នុងភូមិសាស្ត្រខេត្តព្រះវិហារមានជនជាតិកួយរស់នៅតាំងពីដើមកំណើត និងយូរលង់មក ហើយគឺតាំងពី៦០០ឆ្នាំមុនគ្រឹសសករាជ្យយោងតាមប្រវត្តិសាស្ត្រខ្មែរដែលនិយាយពីស្ថានីយ៍បុរេប្រវត្តិសាស្ត្រ **ម្លូព្រៃ** ដែលក្នុងនោះគឺមានជនកួយរស់នៅមុនគេ ដោយមានសំណាក់ និងឈ្មោះទីតាំងជាច្រើនជាសាកួយ និងយោងតាមតាមការចែករំលែករបស់អ្នកស្រុកនៅក្នុងដែនដីស្រុកឆែប។ ក្រៅពីនេះនៅមានការប្រេតិបត្តិប្រពៃណី ការរស់នៅ និងការទំនាក់ទំនងជាភាសាជាភាសាកួយ។

ជាក់ស្តែងចាប់ពីឆ្នាំ១៩៨០ ជនជាតិកួយមាននៅក្នុងស្រុក/ក្រុងទាំង០៧នៃខេត្តព្រះវិហារគឺៈ ស្រុករវៀង ស្រុកជ័យសែន ស្រុកឆែប ស្រុកជាំក្សាន្ត ស្រុកគូលែន ស្រុកសង្គមថ្មី ស្រុកត្បែងមានជ័យ និងក្រុងព្រះវិហារ។

### ៣.១.១ ការសិក្សាស្ថិតិភូមិដែលមានជនជាតិកួយ រស់នៅក្នុងភូមិសាស្ត្រស្រុករវៀង




នៅក្នុងស្រុករវៀងមានជនជាតិកួយរស់នៅពីដើមកំណើតនិងយូរលង់មកហើយមុនឆ្នាំ

ដែលមានចំនួន ០៩ ឃុំគឺៈ

1. ឃុំរក្សា មាន០៣ ភូមិ (កក់ពោន សំរោង ដូនម៉ា)
2. ឃុំរហ័ស មាន០១ ភូមិ (អន្លង់ស្វាយ)
3. ឃុំរូសរាន់ មាន០២ ភូមិ (ទន្លាប់ ទំនប់)
4. ឃុំរុងរឿង មាន០២ ភូមិ (ស្រែធំ បុសពៃ)
5. ឃុំរបៀប មាន០២ ភូមិ (បឹង អូ)
6. ឃុំរតនៈ មាន០២ ភូមិ (សំរិត សំព្រាង)
7. ឃុំរៀបរយ មាន០២ ភូមិ (បង្កួន ស្រែ)
8. ឃុំរម្មណី មាន០៥ ភូមិ (ស្រែធ្នង់ ភ្នំដែក រំចេក អូរពោធិ៍ ជីអភាក)
9. ឃុំរមទម មាន០៤ ភូមិ (បង្កើនផល ស្វាយដំណាក់ចាស់ ស្វាយដំណាក់ថ្មី ត្រពាំងទន្ទឹម)។
10. ឃុំរុងរឿង មាន០១ ភូមិ (ភូមិស្រែធំ)

### ៣.១.២. ការសិក្សាស្ថិតិភូមិដែលមានជនជាតិកួយ រស់នៅក្នុងភូមិសាស្ត្រស្រុកជាំក្សាន្ត




នៅក្នុងស្រុក ជាំក្សាន្ត មាន ជនជាតិកួយរស់នៅពីដើម កំណើត ចំនួន ០៦ ឃុំគឺ:

1. ឃុំព្រីងធំ
2. ឃុំទឹកក្រហម
3. ឃុំរំដោះស្រែ
4. ឃុំ យាង
5. ឃុំកន្ទួត
6. ឃុំស្រអែម

### ៣.១.៣ ការសិក្សាស្ថិតិភូមិដែលមានជនជាតិកួយ រស់នៅក្នុងភូមិសាស្ត្រស្រុក គូលែន




នៅក្នុងស្រុក គូលែន មាន ជនជាតិកួយរស់នៅពីដើម កំណើត និងយូរលង់មុនឆ្នាំ ចំនួន ០៤ ឃុំគឺះ

1. ឃុំគូលែនត្បូង
2. ឃុំត្បែងពីរ
3. ឃុំគូនលែនជើង
4. ឃុំស្រយ៉ង់

### ៣.១.៤ ការសិក្សាស្ថិតិភូមិដែលមានជនជាតិកួយ រស់នៅក្នុងភូមិសាស្ត្រស្រុក ត្បែងមានជ័យ




នៅក្នុងស្រុកត្បែងមានជ័យ មានជនជាតិកួយរស់នៅពីដើមកំណើត និងយូរលង់មកហើយ ចំនួន **០៤** ឃុំគឺ៖

1. ឃុំប្រមេរ មាន០៣ ភូមិ (ប្រមេ បុសធំ ស្រែព្រាង)
2. ឃុំពោធិ៍ មាន០១ ភូមិ (អូរកក់)
3. ឃុំឈានមុខ មាន០៣ ភូមិ (បាក់កាំ សេដ្ឋកិច្ច មហាផល)
4. ឃុំព្រះឃ្លាំង មាន០២ ភូមិ (ក្រាំងដូង អន្លង់ស្វាយ)

នៅក្នុងឃុំព្រះឃ្លាំងមានភូមិបូរាណចំនួន០៣គឺ (ភូមិអូបាក ភូមិសាមគ្គី និងភូមិដូង) ដែលមានពីសម័យសង្គមរាស្ត្រនិយម នៅរបបខ្មៅងងិត (៣ឆ្នាំ៨ខែ២០ថ្ងៃ កម្ពុជាប្រជាធិប្បតេយ្យ ភូមិទាំងនេះត្រូវបានប្រែក្លាយជាវាលពិឃាត (កន្លែងធ្វើទរុណកម្ម និងមនុស្សឃាតដ៍ឃោឃៅ) ដូច្នេះជនជាតិកួយត្រូវបានសម្លាប់ដោយរបបប៉ុលពត។

ចាប់ពីឆ្នាំ១៩៨០មក ជនជាតិកួយបានទៅរស់នៅតាមភូមិផ្សេងៗទៀតក្នុងរូបភាពរកដីកសិកម្ម និងបំលាស់គ្រួសារ និងការរៀបចំគ្រួសាររបបដីសង្គមកិច្ច និងជំលៀសពីសង្គ្រាមផ្ទៃក្នុង។

## ៤. ព័ត៌មានជនជាតិគួយ

### ៤.១ អំពីជនជាតិគួយ

៤.១.១ តើជនជាតិគួយជានរណា? មកពីណា? មានអត្តសញ្ញាណដូចម្តេច?

ផ្អែកតាមការសិក្សាសិក្យាស្រាវបែបចូលរួមពីបញ្ញាជនគួយចាស់ជំនាន់មុន និងអ្នកដឹកនាំសហគមន៍ បានបញ្ជាក់ឲ្យដឹងថា ជនជាតិគួយមានភាសា មានវប្បធម៌ មានអត្តសញ្ញាណ មានប្រពៃណី និងមានជាតិពិន្ទុជាដើម ។ល។ មកទល់នឹងបច្ចុប្បន្នគឺនៅភាគខាងជើងប្រទេសកម្ពុជា។

### ៤.២. អត្ថន័យទូទៅអំពីជនជាតិគួយ

ពាក្យគួយផ្តើមចេញពីតួអក្សរដោយមានព្យញ្ជនៈ និងស្រៈដូចខាងក្រោម៖

**ក៖** មានន័យថា: កកើត កសាង ការពារ ធ្វើឲ្យមានរូបរាង បង្កើតឡើង ចាប់ផ្តើមបង្កើត ជាដើម ។ល។ ហើយចាស់ៗបូរាណតែងពោលថា កឈ្នាង កវែក កឆ្នាំង កគ្រុស កជាលជាដើម ។ល។

បន្ថែមស្រៈ **អួ** (ួ) > **គួ** មានន័យថា រស់នៅ នៅរស់ មានវត្តមាន តាំងទីលំនៅ ។ល។

**យ៖** ប្រហែលមកពីយាក់ សំដៅលើពាក្យស្ត្រីដែលគេចាត់ទុកថាជាអ្នកមានចំណេះដឹងក្នុងការផ្តល់ដំណឹង ផ្តល់ពត៌មានក្នុងការពឹងពាក់ ពុំនាក់អាស្រ័យ ពេលមានអាសន្ន ឬពេលមានតម្រូវការគឺគេទៅរកគាត់ដែលគេគោរពបំផុត។ ឧទាហរណ៍ប្រយោគ ឬឃ្លាជាភាសាគួយថា:

- ជាណាយាក់? (យាយ អញ្ជើញទៅណា?) ប្រើគួរសមចំពោះមនុស្សគួរគោរព
- យាក់ ចូវ ណែ អ្ដិត! (សុំអញ្ជើញយាយមកណេះបន្តិច) ពឹងឲ្យជួយមើលការខុសត្រូវ
- ចូវ ប៉ើរ យាក់ អន មីរ កន អ្ដិត! (មករកយាយជួយមើលកូនបន្តិច) ពេលមានធុរៈបន្ទាន់
- ទួង យាក់ មឺ អន! (ខ្លាចក្រែងយាយមិនអោយ) ការព្រួយបារម្ភចំណុចអវិជ្ជមាន

ដូច្នេះហើយ ពាក្យទាំងនេះបង្កើតបានទៅជា **គួយ** ដោយសារតែពាក្យថា **គួយ** នេះគឺបកប្រែជាភាសាខ្មែរថា " **មនុស្ស**" ដូច្នេះនៅពេលមានការផ្តល់និយមន័យពាក្យគួយ គឺជនជាតិគួយនិយាយពីមនុស្សនៅក្នុងលោក នៅក្នុងប្រទេស នៅក្នុងសហគមន៍ គឺពួកគេនិយាយថា**គួយ**។ ចំពោះពាក្យថា**អួយ?** គេប្រើសំដៅលើការនៅមានចម្ងល់ ឬពេលសួរពីអត្តសញ្ញាញមនុស្សប្រភេទណា។ បើនិយាយសំដៅលើជនជាតិគួយ គេនិយាយថា **គួយហែ** មានន័យថាមនុស្សយើង ឬគ្នាយើង ឬក្រុមយើង។ រីឯមនសុស្សដែលមិនមែនជាជនជាតិគួយគេហៅថា **បេកជ៉ង** មានន័យថាក្រុមមនុស្សមិនមែនជាជនជាតិគួយ អាចជាជនជាតិខ្មែរ ជនជាតិព្នង ជនជាតិចារាយជាដើម។ រីឯជនជាតិបរទេស គេហៅថាបារាំង។ រីឯអ្នក

ជំនួញគេហៅថា **ចិន** សំដៅលើអ្នកដូរនៅផ្សារ ឬលក់ដូរតាមតូប លក់ដូរតាមផ្ទះ ហើយពាក្យនេះមិនមែនសំដៅទៅជនជាតិចិនមកពីប្រទេសចិនទេ។

ដូច្នេះ **គួយ** មានន័យថា: ជាក្រុមកុលសម្ពន្ធ ឬក្រុមមនុស្សដំបូងគេដែលរស់នៅតាមតំបន់ក្បែរព្រៃ និងក្បែរព្រៃភ្នំ ដែលអាស្រ័យជីវិតរស់នៅក្បែរព្រៃដែលមានសត្វទៅតាមស្ថានភាពភូមិសាស្ត្រ ដែលប្រែជាភាសាបាលីមានន័យថាមនុស្ស (មនុស្ស) ប្រែជាភាសាថៃមានន័យថាប្រឆាកន (ประชากร) ជាភាសាវៀតណាមមានន័យថាម៉កង៉ឿយ (Mọi người) ភាសាឡាវមានន័យថាឃុន (ຄົນ) ជាភាសាភូមាមានន័យថាលូតយ៉េ (လူတွေ) ជាភាសាអង់គ្លេសមានន័យថាភីភឹល(People)ឬយូមែនHuman។

## ៥. ប្រវត្តិពាក់ព័ន្ធជនជាតិគួយ និងភូមិសាស្ត្រពីបុរាណ និងបច្ចុប្បន្ន

តើជនជាតិគួយជានរណា? ជនជាតិគួយគឺជាប្រភេទមនុស្សដែលចូលចិត្តរស់នៅក្នុងតំបន់ដែលនៅក្បែរព្រៃទាំងព្រៃស្រោង ពាក់កណ្តាលស្រោង និងព្រៃរបោះដែលមានលក្ខណៈ និងការរស់នៅជាមួយសត្វចិញ្ចឹម និងសត្វធម្មជាតិដែលអំណោយផល ហើយបរបាញ់សត្វព្រៃធ្វើជាអាហារ។

តើជនជាតិគួយជាអ្វី? តាមប្រសាសន៍លោកតា **ហង្ស យន** ដែលជាបញ្ញាជនគួយ និងជាមេដឹកនាំក្នុងជួរអង្គភាពរដ្ឋក្រោយសម័យអាណានិគមបារាំងបានលើកឡើងថា ជនជាតិគួយរស់នៅប៉ែកខាងជើងទឹកដីជ្រោយចង្វា (ភូមិសាស្ត្រទឹកដីរវាងទន្លេសាប និងទន្លេមេគង្គពីភ្នំពេញទៅព្រំដែនភ្នំដងរែក (គាត់ថាសម័យពីដើមគួយហៅថាដូចនេះ)។ គាត់បញ្ជាក់បន្ថែមថា: ជនជាតិ**គួយ**ពីដើមពូកែ មានទំនាក់ទំនងជាមួយខ្មែរ សៀម និងឡាវ ហើយជាជនជាតិដែលស្រឡាញ់ព្រៃភ្នំ និងចូលចិត្តរស់នៅបែបធម្មជាតិ ប្រតិបត្តិសាសនាដូនតា និងគោរពអ្នកតាចាស់ស្រុក។

តើជនជាតិគួយមានប្រភពមកពីណា? តាមការស្រាវជ្រាវ ជនជាតិ**គួយ** រស់នៅ និងមានកំណើតដ៏យូរលង់មកហើយ ដែលចូលចិត្តរស់នៅលាក់ខ្លួនក្បែរព្រៃ និងក្បែរភ្នំ សម្ងំសាងសង់លំនៅដ្ឋាន ធ្វើកសិកម្មប្រពៃណីជាដើម។ ជនជាតិគួយជាក្រុមកុលសម្ពន្ធដើមកំណើតដូចជនជាតិផ្សេងៗទៀតដែរមុនឈានដល់ការថយចុះ។ តាមការស្រាវជ្រាវ ជនជាតិគួយក៏មាននៅប្រទេសឥណ្ឌាទំនងជាមានកត្តាជំរុញឲ្យជនជាតិគួយមួយចំនួន សម្រេចរស់នៅដោយបំលាស់ពីកន្លែងមួយទៅកន្លែងមួយទៀត។ បន្ទាប់មកជនជាតិគួយបានចលនារស់នៅក្នុងទឹកដីសុវណ្ណភូមិ ជាមួយជនជាតិមន ជនជាតិសៀម និងជនជាតិខ្មែរ ហើយបានផ្សារភ្ជាប់ឈាមជ័រជាមួយគ្នាបង្កើតបានជនជាតិមួយដែលភាសាគួយហៅថា ម៉ង ឬម័ង មានន័យថាអ្នកទាំងអស់គ្នា អ្នករាលគ្នា (សំដៅលើក្រុមមកពីប្រភពផ្សេងគ្នា)។ ដោយមានភាសាស្រដៀងគ្នានឹងជនជាតិដើមផ្សេងៗទៀត។ នៅវេជ្ជកាលមួយដែលប្រទេសលើ

ពិភពលោកមិនទាន់សំបូរបែប ជនជាតិកួយស្ថិតក្រោមការគ្រប់គ្រងដោយប្រទេសជិតខាង ដែលប្រទេសជិតខាងនោះបានគ្រប់គ្រង ដែលកួយតែងតែនាំសួយសារ (គ្រឿងចំបាំង សាស្ត្រាវុធ ក្បួន វិជ្ជាសិល្បៈផ្សេងៗជួយស្ដេចផងដែរ។ ក្រោយមកស្ដេចជំនាន់ពីបូរាណបានកោះហៅអ្នកដឹកនាំផ្សេងៗតាមប្រទេសតូចៗទាំងអស់ទៅជួបជុំគ្នា ដោយសារតែស្ដេចចក្រព័ត្រនៃមហាអំណាចភាពចាស់ជរា និងនឿយហត់ក្នុងការគ្រប់គ្រង ស្ដេចអង់នេះបានសាកសួរទៅកាន់អ្នកដឹកនាំផ្សេងៗទៀតថា: តើអ្នកដឹកនាំតាមជនជាតិណាខ្លះដែលចង់បានឯករាជ្យ និងចង់បានការរស់នៅ និងការគ្រប់គ្រងដោយសាសន៍ខ្លួនឯង? អ្នកដឹកនាំតាមជនជាតិបានទទួលយកចំណង់ចំណូលចិត្តរៀងៗខ្លួនដូចជា: ក្រុមជនជាតិកួយបានជ្រើសរើសយកដី ព្រៃ ព្រៃភ្នំ និងសត្វជាដែនដីគ្រប់គ្រង (ការនិទានរឿងដោយលោកអ៊ុម្នាក់ជាជនជាតិកួយនៅភូមិប៉ាលហាល)។

## ៥.១ អំពីជនជាតិកួយនៅតំបន់អាស៊ី

យោងតាមការសិក្សាស្រាវជ្រាវផ្ដើមចេញពីការនិទានរឿងដោយចាស់ទុំបញ្ជាក់ថា ជនជាតិកួយបានបំបែកខ្លួនចេញពី **ក្រុមមន** មករស់នៅតាមដងទន្លេមេគង្គដែលមានព្រៃ មានភ្នំ មានសត្វ ក្នុងដែនដីមួយកាលពីសម័យបូរាណ ហើយមានប្រវត្តិកសាងបដែនដីរបស់ខ្លួននៅចន្លោះភាគខាងជើងប្រទេសកម្ពុជា ខាងកើតប្រទេសថៃ និងខាងលិចប្រទេសឡាវ។ ភាគច្រើនជនជាតិកួយមានរស់នៅតាមតំបន់ភូមិសាស្ត្រដែលមានប្រសាទតូចធំ) ដោយមានតំបន់ជំនឿជាច្រើនពាក់ព័ន្ធទៅជនជាតិកួយ។ ក្រោយមកជនជាតិកួយបានស្ថិតក្នុងដែនដីដែលគ្រប់គ្រងដោយអាណាចក្រខ្មែរដោយបានចូលរួមកសាងប្រាសាទធំៗជាច្រើនដូចជា: ប្រាសាទអង្គរវត្ត ប្រាសាទព្រះវិហារ ប្រាសាទកោះកេរ្តិ៍ ប្រាសាទព្រះខ័ណ្ឌ និងប្រាសាទសំបូរព្រៃគុប។ល។ ក្រៅពីនេះនៅមានប្រសាទតូចៗជាច្រើនទៀតដែលជនជាតិកួយបានចូលរួមកសាង។ ភស្តុតាងជាក់ស្ដែងបានបញ្ជាក់ត្រង់ថាទីណាមានប្រសាទទីនោះមានភូមិដែលមានជនជាតិកួយរស់នៅមុនគេ ដូចជាក្បែរប្រាសាទព្រះវិហារគឺមានភូមិសាអែមចា កន្ទួត និងភូមិដែលមានជនជាតិកួយរស់នៅមុនឆ្នាំ២០០០។ នៅទឹកដីខេត្តព្រះវិហារ មុនឆ្នាំ១៩៩០ គឺមានជនជាតិកួយភាគច្រើនបានរស់នៅនៅតាមភូមិនិយាយតែភាសាកួយ ក្រោយឆ្នាំ១៩៩០ ក្រោយសង្គ្រាមស៊ីវិលបានបញ្ចប់ជនជាតិកួយមានសិទ្ធិសេរីភាព និងសុខសន្តិភាព ដោយបានជួបជុំគ្រួសារប្រកបរបរកសិកម្មតាមចំណោះដឹង និងប្រពៃណីនៅតាមភូមិ ឃុំ ស្រុកផ្សេងលក្ខណៈរាយប៉ាយ និងផ្តុំគ្នានៅតាមភូមិផ្សេងៗ។ ចាប់ពីឆ្នាំ២០០០មកបន្ទាប់ពីសន្តិភាពពេញលេញ និងមានការអភិវឌ្ឍន៍ ជនជាតិខ្មែរ និងជនជាតិកួយបានទំនាក់ទំនង និងរស់លាយគ្នា ផ្សារភ្ជាប់ជាសហគមន៍ជាមួយគ្នាក្នុងភូមិ ក្នុងឃុំ ក្នុងស្រុក និងក្នុងខេត្ត។

ក្រៅពីជនជាតិកួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជនជាតិកួយកួយមានដែនដីនៅស្ថិតនៅក្នុងព្រះរាជាណាចក្រថៃ និងមួយចំនួនទៀតស្ថិតក្នុងដែនដីសាធារណៈប្រជាមានិតឡាវ។ នៅក្នុងស្ថានីយ៍បុរេប្រវត្តិសាស្ត្រខ្មែរ ជនជាតិកួយក៏មានរាជធានីមុនគេគឺនៅរាជធានីម្លូព្រៃ ជាស្ថានីយ៍ម្លូព្រៃដែលជនជាតិកួយធ្វើសម្ភារៈប្រើប្រាស់ពីឆ្អឹងសត្វ និងក្រោយមកជនជាតិកួយចេះជាន់សន្លងស្លដែក ក្រោយមកជនជាតិកួយចេះដុតដែកដំដែកធ្វើសំភារៈ ក្រោយមកបានកែច្នៃវត្ថុធាតុដើមជាសំភារៈ។

## ៦.ពហុភាសាកួយ និងសំនៀងតាមតំបន់

### ៦.១ តារាងពាក្យកួយបកប្រែជាភាសាខ្មែរ និង អង់គ្លេស

| ចាក់ផន់កួយ = Human Body = ខ្លួនប្រាណរបស់មនុស្ស (ភាសាកួយសំនៀងអ្វ៊) | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ចាក់ហិនកួយ = Human Body = ខ្លួនប្រាណមនុស្ស (ភាសាកួយសំនៀងអ្រ៊ី) | | | | | | | | |
| ភាសាអង់គ្លេស | ភាសាខ្មែរ | ភាសាកួយសំនៀ អ្វ៊ | ភាសាកួយសំនៀង អ្រ៊ី | | | | | |
| | | | សម្រេចយកពាក្យ | ភូមិបង្កើនផល | ភូមិអណ្តាស | ភូមិចង្ហូរខ្នា | ភូមិកូនក្អែក | ភូមិវាលវែង |
| Head | ក្បាល | ប៉្លូ | ប្លើ | ប្លើ | ប្លើ | ប្លើ | ប្លើ | ប្លើ |
| Hair | សក់ | សក់ | សុកប្លើ | សុកប្លើ | សុកប្លើ | សុក | សុក | សុក |
| Eye | ភ្នែក | មាត់ | ម៉ាទ់ | ម៉ាទ | ម៉ាទ់ | ម៉ាទ់ | ម៉ាទ់ | ម៉ាទ់ |
| Nose | ច្រមុះ | មុះ | មុស | មុស | មុស | មុស | មុះ | មុះ |
| Mouth | មាត់ | ត្នោស | ត្នូស | ត្នូស | ត្នូស | ត្នូស | ត្នូស | ត្នូស |
| Ear | ត្រចៀក | ក្តោរ | ឡាក្តូរ | ឡាក្តូរ | ស្លាក្តូរ | ស្លាក្តូរ | ឡាក្តូរ | ឡាក្តូ |
| Neck | ក | ត្កុង | ត្កុង | ត្កុង | ត្កុង | ត្កុង | ត្កុង | ត្កុង |
| Elbow | កែងដៃ | កែងតី | កែងតី | កែងតៃ | កែងតី | កែងតី | កែងតី | កែងតី |
| Arm | ដៃ | តី | តី | តៃ | តី | តី | តី | តី |
| Hand | ប្រអប់ដៃ | កម្ប៉ក់តី | ផ្អាប់តី | ប្រអាប់តៃ | ផ្អាប់តី | ផ្អាប់តី | ផ្អាប់តី | ផ្អាប់តី |
| Finger | ម្រាមដៃ | ក្រដយតី | ក្រញ៉ាមតី | ម្រាមតៃ | ក្រញ៉ាមតី | ក្រញ៉ាមតី | ក្រញ៉ាមតី | ក្រញ៉ាមតី |
| Thumb | មេដៃ | ត្រកឹមតី | ត្កឹមតី | ត្កឹមតៃ | ត្កឹមតី | ក្ដឹមតី | ត្កុមតី | ត្កឹមតី |
| Thigh | ភ្លៅ | លូ | លូ | លូ | លូ | លូ | លូ | លូ |
| | កំភួនជើង | ជង្កង់ | ជង្គង់ | ជង្គង់ | ជង្គង់ | ជង្គង់ | ចង្កង់ | ចង្កង់ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| Foot | ប្រអប់ជើង | កម្បក់អ៊្ទឹង | ក្រង់អ្សឹង | ប្រអប់អ្សឹង | ក្រង់អ្សឹង | ក្រង់ជ្សឹង | កន្ទើលយើង | ផ្កាប់អ្សឹង់ |
| Knee | ក្បាលជង្គង់ | ប៉្លត្រកោល | ប្លើគ្គូល | ប្លើគ្គូល | ប្លើគ្គូល | ប្លើគ្គូល | ប្លើគ្គូល | ប្លើគ្គូល |
| Palm | បាតដៃ | ត្លាងតី | ត្លាងតី | បាតតៃ | ត្លាងតី | ត្លាងតី | ត្លាងតី | ត្លាងតី |
| Soles | បាតជើង | ត្លាងអ៊្ទឹង | ត្លាងអ្សឹង | បាតអ្សឹង | ត្លាងអ្សឹង | ក្លាងជ្សឹង | ត្លាងអ្សឹង | ត្លាងអ្សឹង់ |
| Foot | ជើង | អ៊្ទឹង | អ្សឹង | អ្សឹង | អ្សឹង | ជ្សឹង | យ្សឹង | អ្សឹង់ |
| | មេជើង | ត្រកឹមអ៊្ទឹង | ត្តឹមអ្សឹង | ត្តឹមអ្សឹង | ត្តឹមអ្សឹង | ក្តឹមជ្សឹង | ត្តឹមអ្សឹង | ត្តឹមអ្សឹង់ |
| Belly | ពោះ | ពុង | ពុង | ពុង | ពុង | ពុង | ពុង | ពុង |
| Pregnancy | ពោះធំ (មានផ្ទៃពោះ) | ពុងពឹត | ពុងពឹត | ពុងពឹត | ពុងពឹត | ពុងពឹត | ពុងពឹត | ពុពឹត |
| Hip | ត្រគៀក | ឡាត្រពែល | ត្កាគ | ត្កាក | ត្រកាគ | ត្កាគ | ត្រកាគ | ត្រកាគ |
| Cheek | ថ្ពាល់ | ត្របាំ | ត្បាំ | ត្បាំ | ត្បាំ | កាំព្លៀង | ត្បាំ | ត្បាំ |
| Teeth | ធ្មេញ | ក្នែង | ក្នែង | ក្នែង | ក្នែង | ក្នែង | ក្នែង | ក្នែង |
| Lip | បបូរមាត់ | ពារត្រនោស | ពពីត្នួស | ពពីរត្នួស | ពពីត្នួស | ប៉ាពីត្នួស | ពពីត្នួស | ពពីត្នួស |
| Waist | ចង្កេះ | ហ្វែគង | អ្កេង | អ្កេង | អ្កេង | អ្កេង | អង្កេង | អង្កេកង |
| Breast | ដោះ | តោះ | តុះ | តុះ | តុះ | តុះ | តុះ | តុះ |
| Shoulder | ស្មា | ឡាំបាក | ឡាំប៉ាក | ឡាំប៉ាក | ល្បាក | ឡាំប៉ាក | ឡាំប៉ាក | ល្បាក-បាក |
| Back | ខ្នង | គូក | ក្រង់ | ក្រង់ | ក្រង់ | ក្រង់ | ក្រង់ | ក្រង់ |
| Forehead | ថ្ងាស | តឹងហាស | ថ្ងាស | ថ្ងាស | ថ្ងាស | អ៊្ទឹម | ថ្ងាស | ថ្ងាស |

**គ្រួសារ = Family = គ្រួសារ (ភាសាកួយសំនៀង អ៊្វ)**

**គ្រួសារ = Family = គ្រួសារ (ភាសាកួយសំនៀង អ្រ៊ើ)**

| ជាភាសាអង់គ្លេស | ភាសាខ្មែរ | ភាសាកួយសំនៀងអ៊្វ | ភាសាកួយសំនៀង អ្រ៊ើ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | សម្រេចយកពាក្យ | ភូមិបង្កើនផល | ភូមិអណ្តាស | ភូមិចង្ហូរខ្នា | ភូមិកូនក្អែក | ភូមិវាលវែង |
| Aunt | ម្តាយមីង | ម៉ែកេក | ណាំក្រប៉ៃ | ណាំគីក | ណាំក្រប៉ៃ | ណាំក្របៃ | ណាំក្រប៉ៃ | ណាំក្រប៉ៃ |
| Aunt | អ៊ំស្រី | ម៉ែក្រេង | អ្វាស់ក្រប៉ៃ | អ្វាស់ត្រប៉ៃ | អ្វាស់ក្រប៉ៃ | អ្វាស់គ្រប៉ៃ | អ្វាស់ក្រប៉ៃ | អ្វាស់ក្រប៉ៃ |
| Uncle | ពូ | ឱកេក | ណាំ | ណាំ | ណាំកន្ទ្រូល | ណាំកន្ទ្រូស | ណាំ | ណាំ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| Uncle | អ៊ំប្រុស | ឪក្រេង | អ្វាស់កន្ទ្រួស | អ្វាស់កន្ទ្រួស | អ្វាស់កន្ទ្រួស | អ្វាស់កន្ទ្រួស | អ្វាស់កន្ទ្រួស | អ្វាស់កន្ទ្រួស |
| | បង | សាយ | យ៉ាយ | យ៉ាយ | យ៉ាយ | យ៉ាយ | យ៉ាយ | យ៉ាយ |
| | ប្អូន | សែម | សែម | សែម | សែម | សែម | សែម | សែម |
| Husband | ប្តី | ក្បាក | ក្បាក | ក្បាក | ក្បាក | ក្បាក | ក្បាក | ក្បាក |
| Wife | ប្រពន្ធ | កន្តែល | កន្តែល | កន្តែល | កន្តែល | កន្តែល | កន្តែល | កន្តែល |
| Grand Mother | យាយ | យ៉ាក់ | យ៉ាគ់ | យ៉ាក់ | យ៉ាគ់ | យ៉ាគ់ | យ៉ាគ់ | យ៉ាគ់ |
| Grand Father | តា | ចួស | ចួស | ចួស | ចួស | ចួស | ចួស | ចួស |
| We | យើង | ហៃ | ហៃ | ហៃ | ហៃ | ហៃ | ហៃ | ហៃ |
| I/Me | ខ្ញុំ | សោល/កឺ | ក | កៅ | ក | កៅ | ក | ក |
| Girl/Woman | ស្រី | ក្រប៉ៃ | ក្រប៉ៃ | ក្រប៉ៃ | កប៉ៃ | ក្រប៉ៃ | ក្រប៉ៃ | ក្រប៉ៃ |
| Boy/Man | ប្រុស | កន្ទ្រោស | កន្ទួស | កន្ទ្រួស | កន្ទ្រួស | កន្ទ្រួស | កន្ទ្រួស | កន្ទ្រួស |
| Nephew | ក្មួយ | ក្មន/កនក្មន | ក្មន | ក្មន | ក្មន | ក្មន | ក្មន | ក្មន |
| Grandchildren | ចៅ | ចៅ | ចៅ | ចៅ | ចៅ | ចៅ | ចៅ | ចៅ |
| Children | កូន | កន | កន | កន | កន | កន | កន | កន |
| Our father | ឪពុកយើង | ឪហៃ | កូញហៃ | កូញហៃ | កូញហៃ | កូញហៃ | កោញហៃ | កោញហៃ |
| Sister-in-law | ប្អូនថ្លៃស្រី | សែមតាឡៃបក្រប៉ៃ | សែមថ្លៃក្រប៉ៃ | សែមថ្លៃក្រប៉ៃ | សែមថ្លៃក្រប៉ៃ | សែមថ្លៃក្រប៉ៃ | សែមថ្លៃក្រប៉ៃ | សែមថ្លៃក្រប៉ៃ |
| Brother-in-law | ប្អូនថ្លៃប្រុស | សែមតាឡៃបកន្ទ្រោស | សែមថ្លៃកន្ទ្រួស | សែមថ្លៃកន្ទ្រួស | សែមថ្លៃកន្ទ្រួស | សែមថ្លៃកន្ទ្រួស | សែមថ្លៃកន្ទ្រួស | សែមថ្លៃកន្ទ្រួស |
| Sister-in-law | បងថ្លៃស្រី | សាយតាឡៃបក្រប៉ៃ | សាយថ្លៃក្រប៉ៃ | សាយថ្លៃក្រប៉ៃ | សាយថ្លៃក្រប៉ៃ | សាយថ្លៃក្រប៉ៃ | សាយថ្លៃក្រប៉ៃ | សាយថ្លៃក្រប៉ៃ |
| Brother-in-law | បងថ្លៃប្រុស | សាយតាឡៃបកន្ទ្រោស | សាយថ្លៃកន្ទ្រួស | សាយថ្លៃកន្ទ្រួស | សាយថ្លៃកន្ទ្រួស | សាយថ្លៃកន្ទ្រួស | សាយថ្លៃកន្ទ្រួស | សាយថ្លៃកន្ទ្រួស |
| Baby | កូនង៉ែត | កនង៉ា | កនង៉ា | កនង៉ា | កនង៉ារ | កនង៉ា | កនង៉ា | កនង៉ា |
| Small children | កូនតូច | កនតិ | កនកគីក | កនគីក | កនកីក | កនកីក | កនកីក | កនកឹក |
| Older children | កូនធំ | កនពីត | កនពីត | កូនពីត | កូនពីត | កនពីត | កនពីត | កនពីត |
| Children | កូនក្មេង | កនក្មែន | កនក្មែន | កនក្មែន | កនក្មែន | កនក្មែន | កនក្មែន | កនក្មែន |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| Son-in-law/ Daughter in law | កូនប្រសារ | កនព្វេម | កនប្រសារ | កនប៉សារ | កនប្រសារ | កនប្រសា | កនប្រសារ | កនប្រសារ |
| Mother-in-law | ម៉ែក្មេក | ម្ដិក្មេក | មេកចកាន់ | ម្ដេកក្យាកកាន់ | មេកចកាន់ | ម៉េកចកាន់ | មេត | មេក |
| Father-in-law | ឪពុកក្មេក | ឪក្មេក | កូញចកាន់ | កូញក្យាកកាន់ | កូញចកាន់ | កូញចកាន់ | កូញចកាន់ | កោញកាន់ |
| Sister-in-law | បងថ្លៃស្រី | អើយ | សាយថ្លៃក្រប៉ៃ | សាយថ្លៃក្រប៉ៃ | សាយថ្លៃក្រប៉ៃ | សាយថ្លៃក្រប៉ៃ | សាយថ្លៃក្រប៉ៃ | សាយថ្លៃក្រប៉ៃ |
| Brother-in-law | បងថ្លៃប្រុស | អង់ | សាយថ្លៃកន្ទ្រស | សាយថ្លៃកន្ទ្រស | សាយថ្លៃកន្ទ្រស | សាយថ្លៃកន្ទ្រស | សាយថ្លៃកន្ទ្រស | សាយថ្លៃកន្ទ្រស |
| People | មនុស្ស | កួយ | កួយ | កួយ | កួយ | កួយ | កួយ | កួយ |

ចន្ទ័រៗហៃរ័ = Things we do = អ្វីៗដែលយើងធ្វើ (ភាសាកួយសំនៀង អ្ន័)

ចំរើៗដេលហៃរ៉ = Things we do = អ្វីៗដែលយើងធ្វើ (ភាសាកួយសំនៀង ម្រើ)

| ជាភាសាអង់គ្លេស | ភាសាខ្មែរ | ភាសាកួយអ្ន័ | ភាសាកួយ ម្រើ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | សម្រេចយកពាក្យ | ភូមិបង្កើនផល | ភូមិអណ្ដាស | ភូមិចង្ហួរខ្នា | ភូមិកូនក្អែក | ភូមិវាលវែង |
| To eat | បរិភោគបាយ/ហូបបាយ | ចាដយ | ចាដោយ | ចាដោយ | ចាដោយ | ចាដោយ | ចាដោយ | ចាដោយ |
| To drink | ផឹកទឹក | ង៉ចដាក | ង៉ចដាក | ង៉ចដាក | ង៉ចដាក | ង៉ចដាក | ង៉ចដាក | ង៉ចដាក |
| To Sleep | គេង | បិច | បិច | បិច | បិច | បិច | បិច | បិច |
| To cry | យំ | ញ៉ាម | ញ៉ាម | ញ៉ាម | ញ៉ាម | ញ៉ាម | ញ៉ាម | ញ៉ាម |
| To smile | ញញឹម | ញញឹម | ញញឹម | ញញឹម | ញញឹម | ញញឹម | ញញឹម | ញញឹម |
| To read | អាន | អាន | អាន | អាន | អាន | អាន | អាន | អាន |
| To write | សរសេរ | សសេរ | សស៊ីរ | សស៊ីរ | សស៊ីល | សរសេរ | សរសេរ | សសេរ |
| To wash clothes | បោកខោអាវ | បោកខោអាវ | បូកខូអាវ | បូកខូអាវ | បូកខូអាវ | បូកខូអាវ | បូកខូអាវ | បូកខូអាវ |
| To breastfeed | បៅ | ញិម | មឹម | មឹម | មុំ | មុម | មំ | មំ |
| To sleep in hammock | ដេកក្នុងអង្រឹង | បិចឡឹងរយោល | បិចរយោល | បិចណុងយោល | បិចក្នុងរយោល | បិចរំយោល | បិចរយោល | បិចរយោល |
| To mend | ប៉ះ | មាល់ | ប៉ះ | ពា៉ | ប៉ះ | ប៉ះ | ប៉ះ | ប៉ះ |
| To sew | កាត់ដេរ | កាត់ដេរ | កាត់ឌី | កាត់ឌី | កាត់ឌី | កាត់ឌី | កាត់ឌី | កាត់ឌី |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| To dance | រាំ | រាំ | រុំ | រុំ | រាំ | រុំ | រុំ | រាំ |
| To run | រត់ | បោល | ប្រោញ (បូល) | ប្រោញ | ប្រោញ (បូល) | ប្រោញ | បូល | បូល |
| To bathe | ងូតទឹក | ប៉ើយដាក | ប៉ីយដាក | ប៉ីយដាក | ប៉ើយដាក | ប៉ើយដាក | បើយដាក | ប៉ីយដាក |
| To pump water | សប់ទឹក | សប់ដាក | ប្រហុកដាក | សុប់ដាក | ប្រហុកដាក | ស្រុកដាក | ស្រុកដាក | ស្រុកដាក |
| To walk | ដើរ | ប៉ក | រឹច | ពើក | រឹច | រឹច | រឹច | រឹច |
| To stand | ឈរ | ត្បឹង | ត្បឹង | ត្បឹង | ក្បឹង | ត្បឹង | ត្រយឹង | ត្រយឹង |
| To sit | អង្គុយ | ត្ចូវ | ត្ចូវ | ត្គាវ | ត្ចូវ | ត្ចូវ | ត្ចូវ | ត្ចូវ |
| To laugh | សើច | ក្ទាំង | ក្យាំង | ក្យាំង | ក្យាំង | ក្យាំង | ក្យាំង | ក្យាំង |
| Touch | ស្ទាប/ប៉ះ | ចួច | ស្ទាព/ប៉ះ | ស្ទាព/ប៉ា | ស្ទាព/ប៉ះ | ស្ទាព/ប៉ះ | ស្ទាព/ប៉ះ | ស្ទាព/ប៉ះ |
| | ជញ្ជាត់ត្រី | ញ្ជើតកា | អញ្ជាត់ការ | អញ្ជាត់ការ | អញ្ជាត់កា | អញ្ជាត់ការ | អញ្ជាត៉ការ | ការ |
| | រុតត្រី | រឹតកា | រឹតការ | រឹតកា | រឹតកា | រឹតការ | រឹតការ | ពឹកា |
| Brush your teeth | លុបមុខ/ដុសធ្មេញ | ចាស្មាញ | ស្លួស្មាញ់/ដេះក្មែង | ស្លួស្មាញ/ដេះក្មែង | ស្លួស្មាញ/ដេះក្មែង | ស្លួស្មាញ់/ដេះក្មែង | ស្លួស្មាញ់/ដេះក្មែង | ស្លួស្មាញ់/ដេះក្មែង |
| Trail | ផ្លូវ | ក្រណា | ក្នា | ក្នា | ក្នា | ក្នា | កាណា | ក្នា |
| Easy | ស្រួល/ងាយស្រួល | ច្បប | ថ្មើប | ថ្មើប | ថ្មើប | ថ្មើប | ថ្មើប | ថ្មើប |
| | ផ្អែត | ផ្សៀ | ផ្សៀ | ផ្សៀ | ផ្សៀ | ផ្សៀ | ផ្សៀ | ផ្សៀ |
| Hungry | ឃ្លាន | ពាស | ព្យាស់ | ព្យាស់ | ព៉្យាស់ | ព្យាស | ព្យាស់ | ព៉្យាស់ |
| Under | ក្រោម | ក្តប | ក្តើប | ក្តើប | ក្តើប | ក្តើប | ក្តើប | ក្តើប |
| On | លើ | ប៉ង | ប៉ើង | ប៉ើង | ប៉ើង | ប៉ើង | ប៉ើង | ប៉ើង |
| Deep | ជ្រៅ | ន្រ្ទួ | អន្រ្ទួ | ន្រ្ទួ | អន្រ្ទួ | អន្រ្ទួ | អន្រ្ទួ | អន្រ្ទួ |
| Shallow | រាក់ | ន្តល់ | អន្តើរ | អន្តើរ | អន្តើលរ | អន្តើ | អន់តើ | អន់តើ |
| Divorce | លែង(ប្តី/ប្រពន្ធ) | ផ្តាស | ប្តះ(ក្យាក,កន្តែល) | ប្តះ(ក្យាក,កន្តែល) | ប្តះ,ក្យាក,កន្តែល | ប្តះ,ក្យាក,កន្តែល | ប្តះ,ក្យាក,កន្តែល | ប្តះ,ក្យាក,កន្តែល |
| Sleeping | ដេកលក់ | បិចល្ងៀត | បិចល្វែត | បិចល្វែត | បិចល្វែត | បិចល្វែត | បិចល្វែត | បិចល្វែត |
| Speak | និយាយ | ផ្ទុង | ច្រោយ/ម្យាយ | ម្យាយ | ច្រោយ | ច្រោយ/ម្យាយ | ច្រោយ | ច្រោយ |
| Know | ចេះ | ជៀង | ក្ងែន | ក្ងែន | ក្ងែន | ក្ងែន | ក្ងែន | ក្ងែន |
| Previous | មុន | ញោង | ញ្ជួង | ញ្ជួង | ញ្ជួង | ញ្ជួង | ញ្ជួង | ញ្ជួង |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| Eat | ហូប | ចា | ចារ | ចា | ចា | ចា | ចារ | ចារ |
| Wrong | ខុស | លួស | លស | លស | លស | លស | លស | លស |
| Right | ត្រូវ | ក្រែ | ក្រែ | ក្រែ | ក្រែ | ក្រែ | ក្រែ | ក្រែ |
| Look/See | មើល | មី | មែ | មែ | មែ | មែ | មែ | មែ |
| What | អ្វី/ស្អី | ន្ទ័រ | ន្ទ្រី/ចំរើ | ន្ទ្រី/ចំរើ | ន្ទ្រើ/ចំរើ | អន្ទ្រើ | ចំរើ | ចំរើ |
| See | គន់ | ត្មោយ | ត្វង់ | ត្វង់ | ត្វង់ | គ៉យ | ត្វង់ | ត្វង់ |
| Fishing | ស្ទូចត្រី | ត្បាស់កា | ត្បុះការ | ត្បុះការ | ត្បុះការ | ត្បុះការ | ត្បុះការ | ត្បុះការ |
| Go | ទៅ | ចៀ | ចី | ជី | ចី | ចី | ចី | ជី |
| Come | មក | ចូវ | ប៉ើក/ចៅ | ចៅ | ប៉ើក | ប៉ើក | ប៉ើក | ប៉ើក |
| Tired | ហត់ | អឺះ | អេះ/អឺស | អឺស | អេះ | អឺស | អេះ | អេះ |
| Want | ចង់ | ស្មៀរ | ស្មៀ/ហ្យេល | ស្មៀ | ស្មៀ | ស្មៀ | ហ្យេល | ហ្យេល |
| Get | បាន | បឺន | ប៉ឺន | ប៉ឺន | ប៉ឺន | ប៉ឺន | ប៉ឺន | ប៉ឺន |
| Take | យក | អ៊ែល | អ៊ែល | អ៊ែល | អ៊ែល | អ៊ែល | អ៊ែល | អ៊ែល |
| Up | ឡើង | សោះ | សោះ | សោះ | សោះ | សោះ | សោះ | សោះ |
| Down | ចុះ | សែង | សែង | សែង | សែង | សែង | សែង | សែង |
| Heavy | ធ្ងន់ | ន្តង់ | អន្តង់ | អ្តង់ | អន្តង់ | អន្តង់ | អន្តង់ | អន្តង់ |
| Mild penalty | ស្រាល | ន្ទាល | ហ្យាល/ង្ហាល | ង្ហាល | អ្ហាល | អន្ទាល | ហ្យាល | ហ្យាល |
| Catch | ចាប់ | កប | កោប | កោប | កោប | កោប | កោប | កោប |
| Release | លែង (គោ/ក្របី) | ប្រោស | ប្រូស(ន្ទ្រក់) ត្រៀក | ប្រូស (ន្ទ្រក់) ត្រៀក | ប្រូស(អន្ទ្រក/ត្រៀក) | ប្រូស | ប្រូស (អន្ទ្រក/ ត្រៀក) | ប្រូសត្រៀក |
| Well | អណ្តូង | ម្យោះ | ម្យោះ | ម្យោះ | ម្យោះ | ម្យោះ | ម្យោះ | ម្យោះ |

ចន្ទ័រៗហៃហចូតពាក់ = Things we wear = អ្វីៗយើងស្លៀកពាក់ (ភាសាកួយសំនៀងអ្វ័)

ចំរើហៃហចូត/ព៉ាក់ = Things we wear = អ្វីៗយើងស្លៀកពាក់ (ភាសាកួយកួយសំនៀង អ្ទ្រើ)

| ជាភាសាអង់គ្លេស | ភាសាខ្មែរ | ភាសាកួយសំនៀងអ្វ័ | ភាសាកួយសំនៀង អ្ទ្រើ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | សម្រេចយកពាក្យ | ភូមិបង្កើនផល | ភូមិអណ្តាស | ភូមិចង្ហូរខ្នា | ភូមិកូនក្អែក | ភូមិវាលវែង |
| Shirt/blouse | អាវ | អាវ | អាវ | អាវ | អាវ | អាវ | អាវ | អាវ |
| pants | ខោ | ខោ | ខូ | ខូ | ខូ | ខូ | ខូ | ខូ |
| Pocket | ហោប៉ាវ | ក្បៀអាវ | ថង់អាវ/ កប៉ាវ | កប៉ាវ | កប៉ៅ | ថង់អាវ | ថងអាវ | ថង់អាវ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| skirt | សំពត់ | អិច | អិច/អែច់ | អិច | អែច់ | អិច | អិច | អិច |
| Sarong | សំពត់ សារុង | អិចសារុង | អិចសរ៉ុង | អិចសរ៉ុង | អែច់សារ៉ុង | អិចសារុង | អិចសារ៉ុង | អិចសារ៉ុង |
| Belt | ខ្សែក្រវ៉ាត់ | ក្សែក្រវ៉ាត់ | ក្សែអង្កេង/ ក្សែកវ៉ាត់ | ក្សែកវ៉ាត់ | ក្សែអង្កេង | ក្សែអង្កេង | ក្សែអង្កេង | ក្សែអង្កេញ |
| Shoes | ស្បែកជើង | ស្បែក ទ្រាប់ | ស្បែកជើង/ ទ្រនាប់អ្សឹង | ស្បែកជើង | ស្បែកជើង | ទ្រនាប់ជ្សឹ ង | ស្បែកអ្សឹង | ស្បែកអ្សឹង |
| Hat | មួក | មោក | មួក | ម៉ួក | មួក | មួក | មួក | មួក |
| Glasses | វ៉ែនតា | វ៉ាន់តា | វ៉ាន់តា/វែ នតា | វ៉ាន់តា | វែនតា | វែនតា | វ៉ែនតា | វ៉ែនតា |
| Watch | នាឡិកាដៃ | នាឡិកាតី | នាឡិការតី/ នារកាតី | នារកាតៃ | នាឡិតាតី | នាលិកាតើ | នាឡិកាតី | នាឡិការតី |
| Ring | ចិញ្ចៀន | ញ្ចៀន | ចិញ្ចៀន/ អ្ញៀន | អ្ញៀន | អ្ញាន | ចិញ្ចៀន | ចិញ្ចៀន | ចិញ្ចៀន |
| Earring | ក្រវិល | រអ្វែល | កវិល/ក្រវិល | កវិល | កវិល | ក្រវិល | ក្រវិល | ក្រវិល |

ន្ទ័រន្ទីតួនដុង = Things around the house = របស់របរតាមផ្ទះ (ភាសាកួយសំនៀងអ្ន័)

អន្ទ្រីអន្ទ្រីតាមដុង = Things around the house = របស់របរតាមផ្ទះ (ភាសាកួយសំនៀងអ្ន្រី)

| ជាភាសាអង់គ្លេស | ភាសាខ្មែរ | ភាសាកួយសំនៀងអ្ន័ | ភាសាកួយសំនៀងអ្ន្រី | | | | | |
|---|---|---|---|---|---|---|---|---|
| | | | សម្រេចយកពាក្យ | ភូមិបង្កើនផល | ភូមិអណ្ដាស | ភូមិចង្ហូរខ្នា | ភូមិកូនក្អែក | ភូមិវាលវែង |
| House | ផ្ទះ | ដុង | ដុង | ដុង | ដុង | ដុង | ដុង | ដុង |
| Roof | ដំបូលផ្ទះ | តម្បូលដុង | តំប៊ូលដុង/តឹ មប៊ូលដុង | តំប៊ូលដុង | តំប៊ូលដុង | តំប៊ូលដុង | តឹមប៊ូលដុ ង | តឹមប៊ូលដុង |
| Stairs | ជណ្ដើរ | ន្ទ្រ័ង | ចន់រ៉ង/ចន់ ទ្រង់ | ចន់រ៉ង | ចន់រ៉ង | ចន់ទ្រង់ | ចន់រ៉ង | ចន់រ៉ង |
| Door | ទ្វារ | ទ្វារ | ទ្វ៉ារ/ទ្វ៉ាល | ទ្វ៉ារ | ទ្វ៉ាល | ទ្វារ | ទ្វ៉ា | ទ្វ៉ារ |
| Bed | គ្រែ | គ្រេ | គ្រែ | គ្រែ | គ្រែ | គ្រែ | គ្រែ | គ្រែ |
| Mosquito net | មុង | មុង | មុង | មុង | មុង | មុង | មុង | មុង |
| Chair | កៅអី | កៅអី | កៅអី | កៅអី | កៅអ៊ី | កៅអី | កៅអី | កៅអី |
| Table | តុ | តុ | តុ | តុ | តុ | តុ | តុ | តុ |
| Hearthstones | ថ្មជើងក្រាន | ត្នាវប៉ង្កុវ | ត្នោប៉ងហ៊ូ | ត្នោប៉ងហ៊ូ | ត្នោប៉ងហ៊ូ | ត្នោតំពាន់ | តៅតំប៉ាន់ | តៅតំប៉ាន់ |
| Cutting board | ជ្រុញ | ជ្រិញ | ជ្រែញ់ | ជ្រែញ់ | ជ្រែញ់ | ជ្រែញ | ជ្រែញ់ | ជ្រែញ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| Pot | ឆ្នាំង | ដេះ | ដេះ | ដេះ | ដេះ | ដេះ | ដេះ | ដេះ |
| Wok | ខ្ទះ | ផើង | គ្លះតាក | ក្លះតាក | ក្លះតាក | គ្លះតាក | គ្លះតាក | គ្លះតាក |
| Tea kettle | កំសៀវ | ម្សៀវ | កំសៀវ | កំសៀវ | កំសៀវ | កំសៀវ | កំសៀវ | កំសៀវ |
| Lard oil | ខ្លាញ់ | ញ្លែង | អ្សែង/អន់សែញ | អ្សែង | អ្សែង | អន់សែញ | អន់សែញ | អន់សែញ |
| water | ទឹក | ដាក | ដាក | ដាក | ដាក | ដាក | ដាក | ដាក |
| Sticky rice in leaf wrapper | នំអន្សម | ញ្លម | ណឹមអន្សម | ណឹមអ្សម | ណឹមអ្សម | ណឹមអន្សម | ណឹមអន្សម | ណឹមអន្សម |
| Rice | បាយ | ដយ | ដោយ | ដោយ | ដោយ | ដោយ | ដោយ | ដោយ |
| Food to eat with rice | ម្ហូបអាហារ | ម្ហូបចាអ៊ើដយ | បនចា | បនចា | បនចា | បនចា | បនចា | បនចា |
| Bread | នំប៉័ង | នំបាំង | ណឹមប៉័ង | ណឹមប៉័ង | ណឹមប៉័ង | ណឹមប៉័ង | ណឹមប៉័ង | ណឹមប៉័ង |
| Roast chicken | សាច់មាន់អាំង | សាច់ន្ទ្រោយអាំង | សាច់អន្ទ្រួយអាំង | សាច់អន្ទ្រួយអាំង | សាច់អន្ទ្រួយអាំង | សាច់អន្ទ្រួយអាំង | សាច់អន្ទួយអាំង | សាច់អន្ទ្រួយអាំង |
| Spoon | ស្លាបព្រា | ហ្លាព្រា | ស្លាបព្រ៉ា/ច្នក់ | ហ្លាបព្រា | ស្លាបព្រា | ច្នក់ | ស្លាបព្រ៉ា | ស្លាបព្រ៉ា |
| Fork | សម | សម | សម | សម | សម | សម | សម | សម |
| Bowl | ចានសម្ល | ចានក្រឡូង | ចានបាច់ | ចានបាច់ | ចានបាច់ | ចានបាច់ | ចានបាច់ | ចានបាច់ |
| Plate | ចានប៉ាត/ចានបាយ | ចានប៉ាក | ចានភាច/ចានដោយ | ចានប៉ាត/ចានដោយ | ចានផឿក | ចានភាច/ចានដោយ | ចានភាគ/ចានដោយ | ចានភាគ/ចានដោយ |
| Basin | ចានគោម | គោម | ចានលូង/គោមតាក | គោមតាក | ចានលូង | ចានក្រលូង | ចានក្រលូង | ចានលូង |
| Bottle | ដប | ដប | ដប | ដប | ដប | ដប | ដប | ដប |
| Drinking glass | កែវ | ចក | កែវ | កែវ | កែវ | កែវ | កែវ | កែវ |
| Clay pot | ក្អម | ក្អម | ត្នើល/ពួច | ទ្នឹល | ត្នើល | ពួច | ត្នើល់ | ត្នើល |
| Water jar | ពាង | ពីង | ប៉ាង/ពាំង | ប៉ាង | ប៉ាង | ពាំង | ប៉ាង | ប៉ាង |
| Bucket | ថាំង | ក្ដាំង | ថាំង | កថាំង | ថាំង | ថាំង | ថាំង | ថាំង |
| Tray | កញ្ច្រែង | កញ្ច្រែង | កញ្ច្រែង | កញ្ច្រែង | កញ្ច្រែង | កញ្ច្រែង | កញ្ច្រែង | កញ្ច្រែង |
| Winnowing tray | ចង្អេរ | ញ្លាត់ | ព្លឹត/ព្លើត់ | ព្លឹត | ព្លឹត | ព្លឹត | ពើត់ | ពើត់ |
| Tin/can | កំប៉ុង | ក្ប៉ុង | កំប៉ុង | កំប៉ុង | កំប៉ុង | កំប៉ុង | កំប៉ុង | កំប៉ុង |
| Mat | កន្ទេល | ពពារ | ក្ដង | ក្ដង | ក្ដង | ក្ដង | ក្ដង | ក្ដង |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| Broom | អំបោស | រម្បោស | រំប៉ូស | រំប៉ូស | រ៉មប៉ូស | រ៉ម់ម៉ូស | រំប៉ូស | រំប៉ូស |
| candle | ទៀន | ទេន | ទាន | ទៀន | ទាន | ទាន | ទាន | ទាន |
| Lamp | ពិល | ចង្កេង | ពិល | ពិល | ពិល | ពិល | ពិល | ពិល |
| Umbrella | ឆ័ត្រ | ឆាត់ | ឆ័ត្រ | ឆ័ត្រ | ឆ័ត្រ | ឆ័ត្រ | ឆ័ត្រ | ឆ័ត្រ |
| Iron | ឆ្នាំងអ៊ុត | ដេះអ៊ុត | ដេះអ៊ុត | ដេះអ៊ុត | ដេះអ៊ុត | ដេះអ៊ុត | ដេះអ៊ុត | ដេះអ៊ុត |
| Money | លុយ | កាក់ | លុយ | លុយ | លុយ | លុយ | លុយ | លុយ |
| Book | សៀវភៅ | ស្ភៅ | ស្ភៅ/សាភៅ | ស្ភៅ | សាភៅ | សៀវភៅ | សៀវភៅ | សៀវភៅ |
| Pencil | ខ្មៅដៃ | ដីខ្មៅ | ត្មៅតី | ខ្មៅតី | ត្មៅតី | ត្មៅតី | ត្មៅតី | ត្មៅតី |
| Pen | ប៊ិច | ប៊ិច | បិច/ប៊ិច | ប៊ិច | ប៊ិច | ប៊ិច | បិច | បិច |
| Medicine | ថ្នាំ | ចៃក | ចេក | ចេក | ចេក | ចេកក្លង | ចេក | ចេក |
| Scissors | កន្ត្រៃ | កន្ត្រៃ | កន្ត្រៃ | កន្ត្រៃ | កន្ត្រៃ | កន្ត្រៃ | កន្ត្រៃ | កន្ត្រៃ |
| Fingernail clippers | កន្ត្រៃកាត់ក្រចក | កន្ត្រៃកាត់កន្ទ្រេស | កន្ត្រៃរ៉ាច់កន្ទ្រេះ | កន្ត្រៃរិចកន្រេះ | កន្រៃកាត់កន្ទ្រេះតី | កន្ត្រៃរ៉ាច់កន្ទ្រេះ | កន្ត្រៃរាច់កន្ទ្រេះ | កន្ត្រ៉ាច់កន្ទ្រេះ |
| Safety pin | ម្ទុលខ្ទាស់ | កន្លាស់អាវ | អ្ជិលខ្ទើស | អ្ជិលខ្ទើស | ម្ជឹលខ្ទើស | អញ្ជិលខ្ទាស់ | ម្ជិលខ្ទើស | ម្ជិលខ្ទើស |
| String | ខ្សែមួយដុំ | ក្សែមួយដុល | ក្សែម៉ាដឹម | ក្សែមដឹម | ក្សែម៉ាដឹម | ក្សែម៉ាដឹម | ក្សែម៉ាដឹម | ក្សែម៉ាដឹម |
| Comp | ក្រាស | ក្រាស | ក្រាស | ក្រាស | ក្រាស | ក្រាស | ក្រាស | ក្រាស |
| Scrub Brush | ច្រាសបោកខោអាវ | ច្រាសបោកខោអាវ | ច្រាសបូកខូអាវ | ច្រាសបូកខូអាវ | ច្រាសបូកខូអាវ | ច្រាសបូកខូអាវ | ច្រាសបូកខូអាវ | ច្រាសបូកខូអាវ |
| Rice sack | បាវស្រូវ | ក្រុងច្រកស្រ | បាវស្រ/បេប្រ៉ា | បេប្រ៉ា | បាវរ៉ | បាវស្រ | បាវស្រ | បាវស្រ |
| Basket | ជាល | ទាក់ | តំប៉ង | តម្លង់ | កញ្ចាស | ជាល | តំម៉ង | តំប៉ង |
| Flour mill | ត្បាល់កិនម្សៅ | ត្ប៉ាល់កិនម្ដឹះ | ត្វាល់កិនម្សៅ | ត្វាល់កិនម្សៅ | ត្វាល់កឹនម្សៅ | ត្វាល់កិនម្សៅ | ត្វាល់គិនម្សៅ | ត្វាល់គិនម្សៅ |
| Watering can | ថាំងស្រោចបន្លែ | ក្ដាំងជះប៉ន្លែ | ថាំងជះប៉ន្លែ | កថាំងជះប៉ន្លែ | ថាំងជះប៉ន្លែ | ថាំងចះបន្លែ | ថាំងចះបន្លែ | ថាំងចះបន្លែ |
| Radio | វិទ្យុ | រ៉ាប់យ៉ូ | រ៉ាតយោ | រ៉ាតយ៉ោ | វិស៊ុ | រ៉ាតយោ | រ៉ាតយោ | រ៉ាតយោ |
| Bamboo cup | បំពង់ | ទុង | ទុង | ទុង | ទុង | ទុង | ទុង | ទុង |
| fence | របង | រម្បង | អើបង | អើរបង | អើបង | របង | របង | របង |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| Firewood | អុស | អ៊ូស | អ៊ូស | អ៊ូស | អ៊ូស | អ៊ូស | អ៊ូស | អ៊ូស |
| Fire | ភ្លើង | អ៊ូសកាត | អ៊ូសកាត | អ៊ូសកាត | អ៊ូសកាត | អណ្ដាតអ៊ូស | អ៊ូសកាត | អ៊ូសកាត |
| Smoke | ផ្សែង | ប៉ៀក | ប៉ៀក | ប៉ៀក | ប៉ៀក | ប៉ៀក | ប៉ៀក | ប៉ៀក |
| | ក្បុង សម្រាប់ វេចនំ | ក្បុង | ក្បុងទូមវ៉ណឹម | ក្បុងទូមសម្យ | ក្បុងទូមណឹម | ក្បុងទូមណឹម | ក្បុងទូមវ៉ណឹម | ក្បុងទូមវ៉ណឹម |

**គ្រើងតាក = Iron ware = គ្រឿងដែក (ភាសាកួយសំនៀងអ្វ៉ី)**

**គ្រឿងតាក = Iron ware = គ្រឿងដែក (ភាសាកួយសំនៀងអ្វើ)**

| ជាភាសាអង់គ្លេស | ភាសាខ្មែរ | ភាសាកួយសំនៀងអ្វ៉ី | ភាសាកួយសំនៀងអ្វើ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | សម្រេចយកពាក្យ | ភូមិបង្កើនផល | ភូមិអណ្ដាស | ភូមិចង្ហូរខ្នា | ភូមិកូនក្អែក | ភូមិវាលវែង |
| Scale | ជញ្ជីង | ញ្ជីង | ជញ្ជីង | ញ្ជីង | ជញ្ជីង | ជញ្ជីង | ជញ្ជីង | ជញ្ជីង |
| Hand plane | ដែកឈូស | តាកឈូស | តាកឈូស | តាកឈូស | តាកឈូស | តាកឈូស | តាកឈូស | តាកឈូស |
| Hand saw | រណា | រណា | តាករ៉ណាល់ | អាណារ | អាណាល | តាករ៉ណាល់ | អាណារ | អាណារ |
| Drill | ដែកខួង | តាកខួង | តាកខួង | តាកខួង | តាកខួង | តាកខួង | តាកខួង | តាកខួង |
| Hammer | ញញួរ | ញញួរ | ញញួរ | ញញួរ | ញញួរ | ញញួរ | ញញួរ | ញញួរ |
| Nail | ដែកគោល | តាកគោល | តាកគោល | តាកគោល | តាកគោល | តាកគោល | តាកគោល | តាកគោល |
| Machete | កាំបិត | ម្បឹតគូក | អម្តីត | ម្តីត | ម្តីត | អម្តិត | អម្តីត | អម្តីត |
| Screwdriver | ទល់ឡារ៊ីស | ទុលវីស | ទល់ឡាវីស | ទល់ឡាវីស | ទល់លវ៉ីស | ទលឡារ៊ីស | ទល់ឡាវីស | ទល់ឡាវីស |
| Screw | ខ្វៅ | ក្រចៅ | តាកខ្វៅ | ខ្យៅ | ខ្វៅ | តាកខ្វៅ | ខ្វៅតាក | ខ្វៅតាក |
| Adjustable wrench | ម៉ាឡេត | ម៉ាឡេត | ម៉ាឡេត | ម៉ាឡេត | ម៉ាឡេត | ម៉ាឡេត | ម៉ាឡេត | ម៉ាឡេត |
| Axe | ពូថៅ | ប្ល៉ាវ | អម្តីតថៅ | ម្តីតថៅ | ម្តីតថៅ | អម្តិតថៅ | អម្តីតថៅ | អម្តីតថៅ |
| Knife | កាំបិតស្លា | ម្បឹតក្រឡា | អម្តីតឡា | ម្តីតឡា | ម្តីតឡា | អម្តិតឡា | អម្តីតឡា | អម្តីតឡា |
| Razor | កាំបិតកោរពុកមាត់ | ម្បឹតកោរពុក | អម្តីតកូពុកត្នូស | ម្តីតកោរពុកត្មោស | ម្តីតកោរពុក | អម្តិតកូពុកត្នូស | អម្តីតកូពុកត្នូស | អម្តីតកូពុកត្នូស |
| Fishhook | ផ្លែសន្ទូច | ប្លីត្បះ | ព្លីត្បះ | ព្លីត្បះ | ព្លីត្បះ | ព្លីត្បះ | ព្លីត្បះ | ព្លីត្បះ |
| Rake | រនាស់ | រណាស់ | រនះ | រនាស់ | រនះ | រនះ | រនះ | រនះ |
| Sickle | កណ្ដៀវ | ក្ររៀន | ក្ញៀន | ក្ញៀន | ក្ញៀន | ក្ញៀន | ក្ញៀន | ក្ញៀន |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| Hoe | ចប | ចប | ចប | ចប | ចប | ចប | ចប | ចប |
| spade | ចបជីក | ន្ទ្រម | អន់ទ្រាម/ ទ្រៀម | ទ្រៀម | ទ្រៀម | អនទ្រាម | អន់ទ្រាម | អន់ទ្រាម |
| Key | កូនសោរ | កនសោ | កនសោ/សូ/ សោរ | កនសូ | កនសោ/សូ | កនសូ | កនសោរ | កនសោរ |
| Padlock | មេសោរ | សោ | កាន់សូ/មេ សោរ | កាន់សូ | មេសូ | មេសូ | កាន់សោរ | មេសោរ |

ម៉រជិះ = Modes of transport = គ្រឿងទោចក្រយានយន្ត (ភាសាកួយសំនៀងអ្វ៊ែ)

គ្រឿងទោចក្រយានយន្ត = Modes of transport = គ្រឿងទោចក្រយានយន្ត (ភាសាកួយសំនៀងអ្រ្វី)

| ជាភាសា អង់គ្លេស | ភាសាខ្មែរ | ភាសា កួយអ្វ៊ែ | ភាសាកួយអ្រ្វី | | | | | |
|---|---|---|---|---|---|---|---|---|
| | | | សម្រេច យកពាក្យ | ភូមិ បង្កើនផល | ភូមិ អណ្តាស | ភូមិ ចង្ហូរខ្នា | ភូមិ កូនក្អែក | ភូមិ វាលវែង |
| Bicycle | កង់ | កង់ | កង់ | កង់ | កង់ | កង់ | កង់ | កង់ |
| Motorcycle | ម៉ូតូ | ម៉ូតូ | ម៉ូតូ | ម៉ូតូ | ម៉ូតូ | ម៉ូតូ | ម៉ូតូ | ម៉ូតូ |
| Car | ឡាន | ឡាន | ឡាន | ឡាន | ឡាន | ឡាន | ឡាន | ឡាន |
| Truck | ឡានដឹក អីវ៉ាន់ | ឡានតឹកន្ទ័ រន្ទី | ឡានតឹកន្ទ្រើ ន្ទ្រី | ឡានតឹក ន្ទ្រើន្ទ្រី | ឡានតឹកន្ទ្រើ ន្ទ្រី | ឡានតឹកអ ន្ទ្រើអន្ទ្រី | ឡានតឹកអ ន្ទ្រើអន្ទ្រី | ឡានតឹកអ ន្ទ្រើអន្ទ្រី |
| Ship | កប៉ាល់ | កប៉ាល់ | កប៉ាល់ | កប៉ាល់ | កប៉ាល់ | កប៉ាល់ | កប៉ាល់ | កប៉ាល់ |
| Raft | ក្បូន | ក្បូន | គ្បូន | គ្បូន | ក្បូន | ក្បូន | គ្បូន | គ្បូន |
| Rowing boat | ទូក | ទូក | ទូក | ទូក | ទូក | ទូក | ទូក | ទូក |
| Cart | រទេះ | រទេះ | រទេះ | រទេះ | រទេះ | រទេះ | រទេះ | រទេះ |

ចន្ទ្រាន់រ៉ើកនថែម = Animal and bird = សត្វនិងបក្សាបក្សី (ភាសាកួយសំនៀងអ្វ៊ែ)

កញ្ចោមប្រើស់ = Animal and bird = សត្វនិងបក្សាបក្សី (ភាសាកួយសំនៀងអ្រ្វី)

| ជាភាសា អង់គ្លេស | ភាសាខ្មែរ | ភាសា កួយ សំនៀងអ្វ៊ែ | ភាសាកួយសំនៀងអ្រ្វី | | | | | |
|---|---|---|---|---|---|---|---|---|
| | | | សម្រេច យកពាក្យ | ភូមិ បង្កើនផល | ភូមិ អណ្តាស | ភូមិ ចង្ហូរខ្នា | ភូមិ កូនក្អែក | ភូមិ វាលវែង |
| Cat | ឆ្មា | ងាវ | ង៉ាវ | ង៉ាវ | ង៉ាវ | ង៉ាវ | ង៉ាវ | ង៉ាវ |
| Dog | ឆ្កែ | ច | ច | ច | ច | ច | ច | ច |
| Elephant | ដំរី | ចៀង | ចៀង | ចៀង | ចៀង | ចៀង | ចៀង | ចៀង |
| Donkey | លា | លា | លា | លា | លា | លា | លា | លា |
| Buffalo | ក្របី | ត្រៀក | ត្រៀក | ត្រៀក | ត្រៀក | ត្រៀក | ត្រៀក | ត្រៀក |
| Cow | គោ | ន្ទ្រ័ក | អន្ទ្រក់ | ន្ទ្រក់ | អន្ទ្រក់ | អន្ទ្រក់ | អន្ទ្រក់ | អន្ទ្រក់ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| Pig | ជ្រូក | លីក | លីក | លីច | លីច | លីច | លីក | លីក |
| Wild boar | ជ្រូកព្រៃ | លីកក្រូង | លីកកោះ | លីចកោះ | លីចកោះ | លីចកោះ | លីកកោះ | លីកកោះ |
| Crocodile | ក្រពើ | ព្លេវ | ព្លៀវ/ក្របើ | ព្លៀវ | ក្របើ | ក្របើ | ក្របើ | ក្របើ |
| gecko | តុកកែ | តុកកែ | តុកកែ | តុកកែ | តុកកែ | តុកកែ | តុកកែ | តុកកែ |
| Tiger | ខ្លា | ចូសថៅ | ក្លា | ក្លា | ក្លា | ក្លា | ក្លា | ក្លា |
| Bear | ខ្លាឃ្មុំ | ចង្ការ | ក្លាចង់កៅ/ចង្កៅ | ចង្កៅ | ច្កៅ | ក្លាចង់កៅ | ក្លាចង់កៅ | ក្លាចង់កៅ |
| Horn | ស្នែង | ត្កយ | ត្កយ | ត្កយ | ត្កយ | ត្កយ | ត្កយ | ត្កយ |
| Tail | កន្ទុយ | សយ | សយ | សយ | សយ | សយ | សយ | សយ |
| Sheep | ចៀម | ចៀម | ចៀម | ចៀម | ចៀម | ចៀម | ចៀម | ចៀម |
| Goat | ពពែ | ពពែ | ពពែ | ពពែ | ពពែ | ពពែ | ពពែ | ពពែ |
| Monkey | ស្វា | ត្លុង | ស្តេះ | ស្តេះ | ស្តេះ | ស្តេះ | ស្តេះ | ស្តេះ |
| Horse | សេះ | សេះ | សេះ | សេះ | សេះ | សេះ | សេះ | សេះ |
| **ត័ស ភួត**<br> | គោះកង្កែប ឬ ចាក់កង្កែបក្នុងរហែងដីប្រេះ | Find frogs in cracked soil | ពាក្យនេះ ជនជាតិកួយប្រើប្រាស់ក្នុងពេលដែលពួកគាត់បបួលគ្នីគ្នាទៅគាស់ដីនៅតាមត្រពាំងដែលប្រេះរហែង បន្ទាប់ពីរីងទឹកអស់។ នៅពេលស្ថានភាពដីស្ងួតមានប្រហោង ឬប្រេះរហែង ដែលមានកង្កែបរស់នៅក្នុងនោះ ពួកគាត់ជួយគ្នាគាស់ដី រួចហើយពួកគាត់ចាប់យកកង្កែបកួប ឬកង្កែបស្រូវបានយ៉ាងស្រួលដើម្បីយកទៅធ្វើម្ហូបអាហារតាមគ្រួសារ ឬចែកចាយផ្ទះជិតខាង។ សកម្មភាពនេះជាសកម្មភាពប្រពៃណីក្នុងការច្នៃប្រឌិតរកឃើញនូវវិធីថ្មី។ |
| **អក្សរ ឃ** | | | |
| **ឃៀល ភោះ**<br> | ឃ្មុំមានម្ចាស់ ឬ ឃ្មុំព្រៃមានម្ចាស់ | Domestic bees or managed wild bees | ពាក្យនេះ សំដៅលើសត្វឃ្មុំដែលមានលក្ខណៈកាច សាហាវ មិនអាចនរណាទៅក្បែរបាន។ វាជាឃ្មុំដែលជនជាតិកួយឲ្យជំនឿថាជាឃ្មុំលោកតា។ ឃ្មុំនេះបើមាននរណាធ្វើមិនល្អ ឬមានគំនិតមិនល្អ នៅពេលនោះឃ្មុំនឹងទិចក្នុងពេលដែលពួកគាត់ចូលព្រៃ ហើយបើ |

ខុសតំណមនោះឃ្មុំនឹងទិចខ្លាំង។ បើមាននរណាយកឃ្មុំ នៅពេលដែលឃ្មុំនោះដេញនឹង ហើយឃ្មុំនោះដេញរហូតដល់ផ្ទះ ហើយមានអ្នកខ្លះរត់ចូលមុងដើម្បីសុវត្ថិភាពក៏មានដែរ។

## អក្សរ ខ

| | | | |
|---|---|---|---|
| **ខារ អែល**<br> | ជម្ងឺកាចសាហាវរឬជម្ងឺងារបាល | Malignant disease | ពាក្យនេះ ជនជាតិកួយប្រើសំដៅលើស្ថានភាពនៃជម្ងឺដ៏កាចសាហាវ ឬក្នុងស្ថានភាពដ៏អាក្រក់លើសុខភាពសត្វ។ នៅពេលដែលសត្វពាហនៈ ឬសត្វបក្សីក្នុងស្រុកបានស្លាប់រង្គាលនៅតាមផ្ទះ អ្នកស្រុកជនជាតិកួយហៅជម្ងឺនេះថា ងារវាយក។ ដូច្នេះដើម្បីការពារជម្ងឺទាំងនេះមិនឲ្យកើតឡើង អ្នកស្រុកមានជំនឿថាត្រូវតែសែនជូនដូនតា លាងគ្រោះចង្រៃ ដែលធ្វើក្នុងពេលពិធីឡើងអ្នកតា។ |

## អក្សរ ច

| | | | |
|---|---|---|---|
| **ចាំ ព្លី ប៉ាញ់ ចែម**<br>*(តំបន់ក្រ្វី)*<br>**ចាំ ប្លី ប៉ាញ់ ចែម**<br>*(តំបន់អ្វ័)*<br> | ចាំបាញ់សត្វមកស៊ីផ្លែឈើ | Wait for shooting animals or birds to come and eat fruit | ពាក្យនេះសំដៅលើ សកម្មភាពដែលជនជាតិកួយ ជាពិសេសបុរសៗដែលជាក្រុមព្រានព្រៃកាលពីបុរាណ (វចនានុក្រមសម្តេចសង្ឃជួនណាតហៅថាព្រានសត្វ (គ្រាមភាសាកួយ) ដែលចេះដឹងខាងរបៀបបរបាញ់សត្វតាមប្រពៃណីដើម្បីបានសត្វ (ឈ្លូសប្រើស រមាំង ខ្ទីង ខ្លា ជាដើម)។ គោលបំណងដើម្បីយកទៅធ្វើជាអាហារ និងចែកចាយបងប្អូនក្នុងភូមិ ដើម្បីបាន |

| | | | |
|---|---|---|---|
| | | | បរិភោគទាំងអស់គ្នា។ នៅពេលបានសត្វ គឺព្រានសត្វផ្លុំស្នែង ឬផ្លុំអង្គប់ ដើម្បីហៅកម្លាំងអ្នកស្រុកទៅយកសាច់ទុកហូបតាមផ្ទះ។ |
| **ចោះ ឆ្កាខ**  | យកម្រូម ឬចោះម្រូម | Take Marom (stingless bees) by piercing | ពាក្យនេះសំដៅលើសកម្មភាពដែលជនជាតិកួយ ជាប្រពៃណីគឺពួកគាត់មានគ្នាជាក្រុម ដោយបុរសៗនាំគ្នាទៅព្រៃឆ្ងាយពីភូមិ ដើម្បីទៅចោះម្រោម ដែលមាននៅតាមរន្ធដើមឈើ។ ពួកគាត់ប្រើប្រាស់ចំណេះដឹង និងបច្ចេកទេសដើម្បីបានម្រោម ហើយយកទៅចម្រាញ់ យកក្បាលទឹកទៅធ្វើជាឧសថ ឬបរិភាគជាមួយអាហារផ្សេងៗតាមរបៀបរបស់ជនជាតិកួយពីបុរាណ។ |
| **ចេក ទ៉ា់រ គី**  | ថ្នាំវល្លិ៍គុយ | Kui (vine) medicine | ពាក្យនេះសំដៅលើប្រភេទដើមឈើជាវល្លិ៍គុយ ដែលជាទូទៅជនជាតិកួយតែងតែឲ្យតម្លៃក្នុងការថែរក្សា ការការពារ និងការប្រើប្រាស់វល្លិ៍គុយនេះសម្រាប់ព្យាបាលជម្ងឺដែលពាក់ព័ន្ធទៅនឹងស្ថានភាពសុខភាពរបស់ស្ត្រី ដែលភាសាសាមញ្ញជនជាតិកួយហោះថា (ថ្នាំទាស់ទឹកដោះ នៅពេលស្ត្រីកូនខ្ចី)។ ក្រៅពីនេះ គេអាចយកដើមវាស្ងោរទឹកផឹក ឬត្រាំជាមួយស្រាសរជំនួយសសៃរឲ្យដើរស្រួល ហើយគេក៏អាចហូបផ្លែវាដែលមានរស់ជាតិជូអែមទៀតផង។ |

## អក្សរ ឆ

| | | | |
|---|---|---|---|
| **ស្អែខ ម៉ែ**<br> | ជាពាក្យជេរប្រមាថ | An insult | ពាក្យនេះសំដៅលើការជេរទៅលើនរណាម្នាក់ ដែលបានធ្វើឲ្យនរណាមួយខឹងសម្បា ហើយប្រតិកម្មទៅវិញដោយមុខខឹងហើយប្រើពាក្យនេះជាការជេរ ឬបណ្តាសារ ដោយប្រៀបធៀបទៅនឹងស្ថានភាពអ្នកស្លាប់ដែលហើមប៉ោង ហៀរខ្លាញ់ដូចគេយកទៅដុតចោល។ ពាក្យនេះ មានប្រើប្រាស់ដោយជនជាតិកួយនៅតាមតំបន់ខ្លះមិនទូទៅទេ។ |
| ហ្បែង ឡែត | ពាក្យនេះប្រើសំដៅលើទង្វើមិនពេញចិត្ត | Refer to bad commitment of someone. | ពាក្យនេះចាស់ៗកួយ ប្រើភាគច្រើនសំដៅលើទង្វើរបស់នរណាម្នាក់ដែលនិយាយស្តីមិនគប្បី និងមិនមានប្រយោជន៍ ដូច្នេះអ្នកស្តាប់ហាក់ដូចជាមិនពេញចិត្តហើយក៍ប្រើពាក្យនេះតែម្តង។ |
| **អក្សរ ជ** | | | |
| **ជា ប៊ិច ផ្ទាល**<br> | ជីកប្រទាល | Dig succulent plants | ពាក្យនេះ សំដៅលើសកម្មភាពដែលជនជាតិកួយ (ទាំងបុរស ទាំងស្ត្រី) ជីកយកផ្ទាលពីក្នុងព្រៃក្បែរភូមិ ឬឆ្ងាយពីភូមិដែលដុះក្នុងព្រៃធំ។ ការជីកនេះ គេត្រូវទៅគ្នាច្រើននាក់ ដើម្បីការពារសុវត្ថិភាពពីសត្វ (ជ្រូកព្រៃ ខ្លា ដំរី...) ពីព្រោះជ្រូកក៏ឈ្មុលដីស៊ីផ្ទាលនេះដែរ ហើយសត្វខ្លាគឺរកស៊ីជ្រូកព្រៃ។ ពួកគាត់ជីកផ្ទាលនេះ គោលបំណងដើម្បីយកទៅបំពុលត្រីនៅតាមអូ ឬបឹងឲ្យពុលដើម្បីងាយស្រួលចាប់យកទៅធ្វើជាអាហារ។ |

| | | | |
|---|---|---|---|
| **ជួក ញ៉្វក**<br>*(តំបន់ស្រ្វី)*<br>**តាប់ ញ្វក់**<br>*(តំបន់អ្វ៊ែ)*<br> | បុកម្ជូហូប | Make mixed sour fruit (Maju) with spicy dipping sauce | ពាក្យនេះ សំដៅលើសកម្មភាពរបស់ក្រុមស្រ្តី ឬក្រុមយុវជន ឬយុវនារីដែលឯកភាពគ្នាទៅរកផ្លែឈើជូរ ឬផ្លែណាមួយដែលហូបបាន ហើយរួមគ្នាបុកម្ជូររួចហូបជុំគ្នា ដោយបង្ហាញពីការសាមគ្គីគ្នា ក្នុងនោះអ្នកដឹកនាំការបុកម្ជូរគេដាក់ចំនួនផ្លែម្ទេសទៅតាមអាយុរបស់អ្នកបុកម្ជូរ។ នៅពេលហូបគេភ្នាល់គ្នាអំពីការឈ្នះក្នុងការហូប តើនរណាអាចទ្រាំនឹងការហិរបាន។ |
| **ជៀ រិត ភា**<br> | ការទៅរុតត្រី | Fishing with Angrot (Khmer fishing gear) | ជាពាក្យដែលជនជាតិកួយប្រើប្រាស់ក្នុងសកម្មភាពរុតត្រីនៅតាមត្រពាំង បឹងតូច អូរ ឬប្រឡាយ។ ការរុតត្រីធ្វើឡើងក្រោយពីពួកគាត់បានជួបជុំនិងឯកភាពគ្នានៅក្នុងភូមិ ហើយពួកគាត់មានសភារៈសម្រាប់រុតទៅជាមួយផង និងមានវេចបាយ ឬដាក់អង្ករទៅដាំបាយ។ ក្នុងការរុតត្រីគឺតែងតែមានការបួងសួង ឬពោលពាក្យសុំម្ចាស់ព្រៃ ឬម្ចាស់ទឹកដើម្បីឲ្យបានត្រី និងសុំសេចក្តីសុខផងដែរ ដោយសារតែកន្លែងរុតត្រីជាទីតាំងដែលពួកគាត់មានជំនឿថាមានម្ចាស់ថៃទើបមានត្រីរស់នៅកកកុញ និងមាទឹកខ្ជបប្រាំងផងដែរ។ |
| **ជី ស្រែំ ជីស្រ៉ែ**<br>*(តំបន់ស្រ្វី)*<br>**ជៀស្រែំ ជៀស្រ៉ែ** | ទៅស្រែចម្ការ | Go to the farm or plantation | ពាក្យនេះ សំដៅលើសកម្មភាពជាប្រពៃណីដែលជនជាតិកួយ ទៅស្រែ ឬទៅចម្ការជាក្រុម ឬជាគ្រួសារសាច់ញា |

| | | | |
|---|---|---|---|
| *(តំបន់អ្វ័)*<br> | | | តិ។ ពួកគាត់មានស្រែ ចម្ការធំៗទៅតាមស្ថានភាពកម្លាំងអាចធ្វើបាន ដោយមានដីប្រើប្រាស់ដាំដំណាំស្រូវស្រែ ដីត្រៀមចម្ការវិលជុំ ដីទុកចញ្ចឹមសត្វនៅរដូវវស្សា និងដីត្រៀមចែកកូនៗ។ ក្នុងពេលវគ្គបង្កបង្កើនផល ការថែទាំ និងការប្រមូលផល ពួកគាត់ដេកនៅទីនោះជាក្រុមស្រែតំបន់ជាមួយគ្នារហូតដល់ពេលដឹកទិន្នផលស្រូវទៅដាក់ជង្រុកនៅផ្ទះ។ |
| **ជូក កាស៊ីម**<br>*(តំបន់អ្រើ)*<br>**អ្រាត់ កា សោម**<br>*(តំបន់អ្វ័)*<br> | ចូកកំពឹស | Shrimping (by using nets, traps, even handpicking) | ពាក្យនេះ សំដៅលើសកម្មភាពជនជាតិកួយ (ស្ត្រី) ជាប្រពៃណីទៅរកត្រីតាមអូរ ប្រឡាយ និតត្រពាំងដែលមានទឹក និងមានត្រីរស់នៅ។ ពួកគាត់មានគ្នាជាក្រុម និងមានឈ្នាង ដើម្បីចូកកំពឹសផង និងរកត្រីផង។ ត្រី ឬកំពឹសដែលរកបានពីការចូកនេះ គឺមានរស់ជាតិឆ្ងាញ់។ |
| **ជៀ កោប ក្បួត**<br>*(តំបន់អ្រើ)*<br>**ជៀ កប ក្បួត**<br>*(តំបន់អ្វ័)*<br> | ចាប់កង្កែប | Catch frogs | ពាក្យនេះសំដៅលើសកម្មភាព ដែលជនជាតិកួយទាំងប្រុសទាំងស្រី ទាំងក្មេងទាំងចាស់ ប្រើប្រាស់វានៅក្នុងសកម្មភាពដែលពួកគាត់នាំគ្នាទៅចាប់កង្កែប (កង្កែបហ៊ីង កង្កែបត្រូក កង្កែបជ័រ និងកង្កែបកូបជាដើម)។ ក្រោយពីមានភ្លៀងធ្លាក់មួយមេ ឬពីរមេរយ៉ាងច្រើន ហើយមានទឹកនៅតាមថ្លុក ឬតាមត្រពាំង តាមប្រឡាយ តាមអូរនៅដើមឆ្នាំ។ អ្នកស្រុកបានបបួលគ្នាក្នុងភូមិទៅរកចាប់កង្កែបនៅតាមទីតាំង |

| | | | |
|---|---|---|---|
| | | | ដែលមានសម្លេងកង្កែបពោទ័ទ្រហឹង អ៊ឹងកង។ |
| **ឆ្វាត់ ភា**<br> | ជញ្ជាត់ត្រី | Catch fish in shallow water | ពាក្យនេះ ប្រើនៅពេលដែលស្ត្រីជនជាតិកួយនាំគ្នាទៅជញ្ជាត់ត្រីអូរនៅទីតាំងដែលមានទឹករាក់ ឬទឹកដែលបម្រុងនឹងរីង ហើយនៅសល់ត្រីរស់នៅដោយសារតែនៅតាមទីតាំងដែលមានទឹកគឺសម្បូរទៅដោយស្លឹកឈើច្រើន។ ពួកគាត់ទៅដោយមានគ្នាច្រើនដើម្បីសុវត្ថិភាពពីមនុស្ស និងសត្វផ្សេងៗដែលចូលចិត្តរស់នៅតាមអូរដើម្បីចាប់សត្វជាចំណីផងដែរ។ |

## អក្សរ ឈ

| | | | |
|---|---|---|---|
| **ឈូសត្លោល**<br>**ឈូសល័ខ**<br>**ឈូសភាតារ**<br> | ការងារឈូសឈើ ឬ<br>សសេរ ឬក្តា | Wood flattening and inscription | ពាក្យនេះ សំដៅលើសកម្មភាពជនជាតិកួយ (បុរសជាជាងឈើ) ដែលប្រើប្រាស់ចំណេះដឹងក្នុងការងារឈូសសសេរធ្វើផ្ទះ ឈូសឈើធ្វើរទេះ ឬធ្វើដងចប ជ្រនីក ឬឈូសក្តារជាដើម។ ជនជាតិកួយធ្វើដែកឈូសពីឈើ និងដែក ហើយធ្វើសកម្មភាពឈូសសម្អាត់វត្ថុទាំងនោះឲ្យស្អាត។ |

## អក្សរ ញ

| | | | |
|---|---|---|---|
| **ញាម រាល់ ស្តៅ** | យំរាល់យប់ | Cry every night | ពាក្យនេះ សំដៅលើក្មេងយំមិនបានបាត់នៅពេលយប់ ជាទូទៅក្មេងយំយប់ហើយមានលក្ខណៈស្រែកខ្លាំងៗ លួងមិនបាត់យំ ពេលខ្លះយំមិនបានដេកដោយមានអាការៈខុសប្លែកៗ។ ជន |

| | | | |
|---|---|---|---|
| | | | ជាតិកួយមានជំនឿរថាក្មេងនោះខុសអ្វីមួយ ដូច្នេះគេត្រូវយកក្មេងនោះទៅស្តោះផ្លុំ ឬទៅបូលប្រណាក ឬបូលពងមាន់ ឬបញ្ចូលមេមត់ ឬបញ្ជាន់អារក្សដើម្បីរកមូលហេតុ។ ក្រោយពីការរកឃើញមូលហេតុ ក្មេងនោះក៏ឈប់យំ ហើយមានសភាពធម្មតាវិញ។ |

## អក្សរ ជ

| | | | |
|---|---|---|---|
| **ដាក់ ឡាយ**  | ដាក់លាយ/ទ្រូ | Fishing with Leay/Trou (Khmer bamboo fishing gear) | ជាពាក្យ ដែលជនជាតិកួយបានប្រើប្រាស់ចំណេះដឹងក្នុងការរៀបចំទីតាំងសម្រាប់ដាក់លាយ ឬដាក់ទ្រូដើម្បីបានត្រី។ វាជាវិធីបូរាណមួយដើម្បីបានត្រីយកទៅធ្វើម្ហូបអាហារ។ ទីតាំងដាក់គឺស្ថិតនៅតាមអូរ ឬប្រឡាយដែលសំបូរទៅដោយត្រីឡើង ឬត្រីចុះ។ សកម្មភាពនេះ គឺធ្វើនៅរដូវវស្សា និងរដូវរំហើយ នៅពេលដែលទឹកអូរស្រកទឹក។ |
| **ដាក់ អ្ដាក់**  | ដាក់អន្ទាក់ | To trap | សំដៅដល់ សកម្មភាពដែលជនជាតិកួយដែលជាព្រានព្រៃយកសំភារៈ និងឧបករណ៍ទៅធ្វើអន្ទាក់យកសត្វព្រៃ ដូចជាសត្វជ្រូកព្រៃ ប្រើស រមាំង ក្តាន់ខ្ទីងជាដើម។ល។ ដោយប្រើវិធីឧបកិច្ចស្លឹក និងកូកព្រៃដើម្បីសុំសត្វកំបាក់កំបែកយកទៅធ្វើជាអាហារ និងចែកអ្នកស្រុកបានហូបដូចគ្នា។ |

| | | | |
|---|---|---|---|
| **ដុខ ឆៀ**<br> | ផ្ទះចាស់ | Old fashion house | ពាក្យនេះ សំដៅលើផ្ទះចាស់ នៅតំបន់ខ្លះ ជនជាតិកួយនៅពេលមានគូរស្រករ គឺពួកគាត់ចាប់ផ្តើមសាងសង់ផ្ទះមួយខ្ទងតូចសម្រាប់ជាទីជម្រកក្នុងគ្រួសារ ហើយបន្ទាប់មកគ្រួសារនោះមានកូនច្រើនឡើងៗ (កាលពីដើមគ្រួសារនិមួយៗមានកូនយ៉ាងតិច៥នាក់) និងបានចាប់ផ្តើមអារឈើគ្រឿងផ្ទះដោយមានអ្នកស្រុកជួយផងដែរ។ |
| **ដុខ ត្នាយ**<br>*(តំបន់ស្រើ)*<br>**ដុខ ត្នៃ**<br>*(តំបន់អ្វ៊ែ)*<br> | ផ្ទះថ្មី<br>ឬផ្ទះម៉ូតថ្មី | New fashion house | ពាក្យនេះ សំដៅលើផ្ទះដែលសាងសង់ថ្មី ឬម៉ូតថ្មីសម្រាប់គ្រួសារដែលធូធារ ហើយ ជាទូទៅ ពីដើមជនជាតិកួយ នៅពេលសាងផ្ទះគឺពួកគាត់ចេះជួយគ្នាទៅវិញទៅមក ដោយជួយទ្រង់ទ្រាយធំគឺការផ្តុំផ្ទះចំណាយពេលមួយថ្ងៃ និងលើកផ្ទះចំណាយពេលមួយថ្ងៃ ពេលល្ងាចពួកគាត់ចាប់ផ្តើមសែនព្រេនយកថ្ងៃឡើងនៅលើផ្ទះផ្ទះ ដោយមានពិធីសាសនា និងកម្មវិធីកំសាន្ត។ |
| **ដុខ យាក់ ជួស**<br> | ខ្ទមអ្នកតា | Spirit houses | ពាក្យនេះ សំដៅលើទីតាំងដែលមានខ្ទមប្រក់ស្បូវ ឬស្លឹកហើយមានរូបសំណាកអ្នកតា ជាមួយសំភារៈជាគ្រឿងការពាររបស់អ្នកតាចាស់ស្រុក។ ខ្ទមអ្នកតាជាទីតាំងសក្ការៈរបស់ជនជាតិកួយ |

## អក្សរ ត

| | | | |
|---|---|---|---|
| **តាប់ ញក់** | បុកម្ហូបហូប | Eat pickles | ពាក្យនេះ សំដៅលើសកម្មភាពរបស់ក្រុមស្ត្រី ឬយុវជនដែលឯកភាពគ្នាទៅរកផ្លែជូរ ឬផ្លែណាមួយដែលហូបបាន |

| | | | |
|---|---|---|---|
|  | | | ហើយរួមគ្នាបុកម្ទូរ រួចហូបជុំគ្នា បង្ហាញពីការសាមគ្គីគ្នា ក្នុងនោះអ្នកដឹកនាំការបុកម្ទូរគេដាក់ចំនួនផ្លែម្ទេសទៅតាមអាយុរបស់អ្នកបុកម្ទូរ។ នៅពេលហូបគេភ្ជាល់គ្នាអំពីការឈ្នះក្នុងការហូប។ |
| **ត្អុច អែល កា**  | អង្គុយចាំចាប់ ឬកាប់ត្រីតាមអូរ | Catching and cutting fish in stream | ពាក្យនេះ សំដៅវិធីមួយ ដែលជនជាតិកួយពីបូរាណតែងតែនាំគ្នីគ្នាទៅអងចាប់ត្រី ឬកាប់ត្រី ឬដួសត្រីតាមអូរ ឬប្រឡាយ ដោយពួកគាត់រៀបចំជាសម្រះ និងបិតមុខទឹករួចទុកមុខទឹកឲ្យត្រីរត់ចុះរត់ឡើង។ |
| **តាប់ ព័ស ល្ងឹខ**  | បុកអំបិលល្ង | Make sesame salt | ពាក្យនេះ ភាគច្រើនស្ត្រីសំដៅលើជនជាតិកួយ (ស្ត្រី) តែងតែបុកអំបិលល្ងដើម្បីបរិភោគក្នុងគ្រួសារ និងរក្សាទុកបានយូរ ដែលពួកគាត់អាចវេចខ្ចប់ទៅព្រៃសម្រាប់បរិភោគជាមួយនិងបន្លែព្រៃនៅពេលពួកគាត់សម្រាកព្រៃដោយមានភាពងាយស្រួលហូបអាហារតាមព្រៃ ឬទៅចម្ការ ឬតាមស្រែ។ |
| **តាក់ ត្រៀ**  | បេះឬបោចផ្សិត | Pick up mushroom | ពាក្យនេះ ជនជាតិកួយប្រើប្រាស់ជាទូទៅក្នុងសកម្មភាពប្រមូលគ្នីគ្នាទៅបេះផ្សិត ឬទៅរកផ្សិត។ ជាទូទៅគាត់ទៅរកផ្សិតជាក្រុម ដោយមមានឧបករណ៍ប្រើប្រាស់បែបប្រពៃណី។ ពេលខ្លះពួកគាត់វេចខ្ចប់នឹងស្លឹកខ្លុង ឬស្លឹកត្បែង ឬជាល ឬកញ្ជើរដែលយកទៅពីផ្ទះ។ នៅពេលបានផ្សិតពួកគាត់ |

| | | | |
|---|---|---|---|
| | | | អាចលក់ និងទុកហូបក្នុងគ្រួសារ និងអាចចែកចាយទៅដល់សាច់ញាតិក្នុងភូមិផងដែរ។ |
| **តាក់ ព្លី គី** *(តំបន់ក្រ្សី)* **តាក់ ប្លឺ គី** *(តំបន់ភ្ង័)*  | បេះផ្លែគុយ | Pick up Kui (Khmer wild fruit) | ពាក្យនេះ ជនជាតិកួយប្រើប្រាស់ក្នុងរដូវខែពិសាយដែលនៅតាមព្រៃឆ្ងាយពីភូមិ ពួកគាត់បបួលគ្នីគ្នាទៅរកផ្លែគុយដោយប្រើសមត្ថភាពក្នុងការឡើងបេះផ្លែគុយបាន។ ជាទូទៅជនជាតិកួយបេះផ្លែគុយយកទៅបរិភោគជាផ្លែឈើផ្អែមទូទាំងភូមិ ឬជាក្រុមដែលពួកគាត់មានជំនឿថាជាផ្លែឈើឧសថ ។ ក្រៅពីនេះពួកគាត់អាចលក់បានជាប្រាក់ចំណូលដើម្បីទិញគ្រឿងទេសសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ។ |
| **តាក់ ព្លី ឡូខ** *(តំបន់ក្រ្សី)* **តាក់ ប្លឺ ល័ខ** *(តំបន់ភ្ង័)*  | បេះផ្លែព្រីង | Pick up jambolan plum (Pring | ជនជាតិកួយ តែងតែបបួលគ្នីគ្នាទៅបេះផ្លែព្រីងដែលមាននៅតាមវាលស្រែ ឬព្រៃរបោះ ឬព្រៃស្រោង ពួកគាត់ទៅជាក្រុម មានបុរសៗជាអ្នកឡើងដើមអង្រួនផ្លែឲ្យជ្រុះ ដើម្បីអ្នកផ្សេងទៀតជាអ្នកចាំរើសនៅខាងក្រោមដើម ពួកគាត់រើសផ្លែព្រីង ហើយយកទៅហូបនៅភូមិ និងចែកចាយដល់អ្នកផ្សេងៗទៀតនៅក្នុងភូមិដើម្បីហូបកំសាន្ត និងហូបផងពិភាក្សាគ្នាផងដែរ។ |
| **តំបូរ ភា**  | វេចត្រីខ្ចប់ | Make fish dish (Khnab) | សំដៅលើម្ហូបមួយបែបមានរស់ជាតិឆ្ងាញ់ ដែលជនជាតិកួយទាំងបុរសទាំងស្ត្រី តែងតែយកត្រីចង្វារពីអូ ប្រឡាយ ឬត្រពាំងមកលាយផ្សំជាមួយគ្រឿងទេសផ្សេងៗ ដោយវេចខ្ចប់ជាមួយស្លឹក |

| | | | |
|---|---|---|---|
| | | | ឈើពីព្រៃដែលមានទ្រង់ទ្រាយធំ (ខ្លុង មមាំង ត្រសើម អាឡោក រលាយ ត្បែង ....) យកទៅអាំងនឹងភ្លើង បន្ទាប់យកទៅហូបជុំគ្នា ឬចែកគ្នាហូប។ |
| **ឝ្យុះ ភ្នួឝ**  | បបក់កង្កែប | Fish frogs with rods | ពាក្យនេះ ជនជាតិកួយជាបុរស ឬយុវជនតែងប្រើប្រាស់ជាក្រុមនៅក្នុងការទៅបបក់កង្កែបនៅតាមត្រពាំង ឬស្រះក្នុងព្រៃ ដោយប្រើប្រាស់ដៃឬស្សី ឬកូនឈើជាដង ដាក់នុយជាស្បែកកង្កែបរួចបោះចូលក្នុងទឹកត្រពាំងដោយសញ្ញាផ្សេងៗឲ្យកង្កែបដេញលេប។ នៅពេលដែលកង្កែបលេបចូលហើយគេវាត់ឈើ ឬឬស្សីទៅក្រោយដោយជាមួយនឹងកង្កែប។ ការបបកជាវិធីសាស្ត្រមួយដែលជនជាតិកួយប្រើប្រាស់ដើម្បីឲ្យបានកង្កែបកូបច្រើនយកទៅជាអាហារ។ |
| **ឝាក់ ឡា ប្រិច**  | បេះស្លឹកប្រិច | Forage for edible leaves (Prich) | ពាក្យនេះ សំដៅលើសកម្មភាពដែលជនជាតិកួយ (ប្រុស ស្រី) នាំគ្នាទាំងហ្វូងទៅរក និងបេះស្លឹកប្រិចនៅតាមព្រៃដែលនៅឆ្ងាយពីភូមិប្រមាណ១០ គីឡូ អាស្រ័យទៅតាមស្ថានភាពភូមិនៅតាមតំបន់។ ដើមប្រិចមានដុះតាមតំបន់ព្រៃ ឬស្ថានភាពដីដែលមានទីទួល និងមានដំបូក។ អ្នកបេះស្លឹកប្រិចត្រូវមានទឹក បាយ និងម្ហូបទៅជាមួយ ឬក៏មានសត្វឆ្កែទៅអមដើម្បីការពារសុវត្ថិភាពតាមដងព្រៃ។ គេអាចយក |

| | | | |
|---|---|---|---|
| | | | ប្រិចធ្វើជាអាហារ ចែកគ្នាហូប និងលក់ បានជាថវិកាផ្គត់ផ្គង់ជីវភាពផងដែរ។ |
| **តាក់ ឡា អក ខ្ទក់**  | បេះស្លឹកអកខ្វក់ | Forage for edible leaves (Orkhatuk) | ពាក្យនេះសំដៅលើ សកម្មភាពដែល ជនជាតិកួយក្នុងសហគមន៍ទៅបេះ ត្រួយអកខ្វកយកទៅធ្វើជាបន្លែ ឬស្ល ម្ជូបដែលមានរស់ជាតិឆ្ងាញបែបធម្មជាតិ ហើយជាបន្លែឧសថផងដែរ។ អ្នក បេះស្លឹកអកខ្វក់អាចទៅបេះគ្នា២នាក់ ឬគ្នាជាក្រុម ដោយពួកគាត់អាចបេះ បានគ្រប់រដូវ ជាពិសេសរដូវស្លឹកឈើ លាស់ ក្រោយពីភ្លើងខេះរោល។ |
| **តាក់ ឡា ច្រីស**  | បេះស្លឹកច្រេស | Forage for edible leaves (Jres) | ពាក្យនេះសំដៅលើ សកម្មភាពដែល ជនជាតិកួយក្នុងសហគមន៍ទៅបេះ ស្លឹកច្រេសទើបលាស់ខ្ចី យកទៅធ្វើជា បន្លែ ឬស្លកកូរ ឬស្លប្រហើរបានដែល មានរស់ជាតិឆ្ងាញ់បែបធម្មជាតិ ហើយ ជាបន្លែឧសថផងដែរ។ អ្នកបេះស្លឹក ច្រេសអាចទៅបេះគ្នា២នាក់ ឬគ្នាជា ក្រុម ដោយពួកគាត់អាចបេះបានគ្រប់រដូវ ជាពិសេសរដូវស្លឹកឈើលាស់ ក្រោយពីភ្លើងឆេះរោល។ |
| **តាក់ ឡា ចឹខ**  | បេះស្លឹករាំង | Forage for edible leaves (Raing) | ពាក្យនេះ សំដៅលើសកម្មភាពការបេះ ស្លឹករាំង ដែលជនជាតិកួយ (ស្ត្រី) នាំគ្នា ទៅបេះដែលមានដុះនៅតាមមាត់អូរ ឬ មាត់ប្រឡាយ។ ពួកគាត់បេះអមក្នុង សកម្មភាពដងទឹក ឬទៅរកអុសជាដើម។ |

| | | | |
|---|---|---|---|
| **តាក់ ឡា ទូច**<br> | បេះស្លឹកម្ជូត្រមូង | Forage for edible sour leaves (Tramoung) | ពាក្យនេះសំដៅលើសកម្មភាព ដែលជនជាតិកួយប្រើប្រាស់នៅពេលដែលពួកគាត់ទៅបេះស្លឹកទ្រមូង ដើម្បីយកទៅស្លម្ជូរគ្រឿង នៅពេលដែលពួកគាត់បានសាច់ពីព្រៃ ហើយពួកគាត់ជួបជុំគ្នាហូបរួមគ្នា មានកម្មវិធីសប្បាយបង្កើនសាមគ្គីភាព។ |
| **តាក់ ឡា ស្នេញ**<br> | បេះស្លឹកម្ជូរធ្នឹង | Forage for edible sour leaves (Thnoeng) | ពាក្យនេះ សំដៅលើសកម្មភាពស្ត្រីជនជាតិកួយទៅបេះស្លឹកធ្នឹងដើម្បីធ្វើជាម្ជូរសម្រាប់ស្លហូបនៅពេលពួកគាត់បានសាច់ពីព្រៃ។ |
| **តាក់ ត្រៀ ខោក**<br> | បេះផ្សិតក្ងោក | Pick up Kangork mushroom | ពាក្យនេះសំដៅលើសកម្មភាពដែលជនជាតិកួយ (ស្ត្រី) នាំគ្នាទៅបេះផ្សិតក្ងោកដែលមានដុះនៅតាមវាលដែលមានព្រៃ និងនៅមាត់ព្រៃ។ ផ្សិតនេះបានធ្វើឲ្យជនជាតិកួយសប្បាយចិត្ត និងបង្កើនសាមគ្គីភាពដែលអាចធ្វើឲ្យពួកគាត់យកបន្លែទៅធ្វើម្ហូប និងអាចលក់បានប្រាក់ចំណូល។ |
| **ត្លួម ចែក**<br> | ដើមថ្នាំ | Medicinal plants | ពាក្យនេះសំដៅលើប្រភេទដើមឈើដែលជនជាតិកួយកំណត់សំគាល់ថាជាប្រភេទដើមឈើឧសថបូរាណ ដែលជនជាតិកួយតែងតែមានជំនឿលើដើមឈើដែលមានភាពស័ក្តសិទ្ធក្នុងការព្យាបាលជម្ងឺផ្សេងៗ។ |

| | | | |
|---|---|---|---|
| **តើល ភ្លូខ តាក**  | ទួលអាចម៍ដែក | Arch Dek hill | ពាក្យនេះ សំដៅដល់ទីតាំង ឬដីព្រៃដែលមានស្ថានីយស្លដែកពីបូរាណ ដែលជនជាតិកួយពីបូរាណបានយកទីតាំងទួល ឬដីខ្ពស់ដើម្បីបង្កើតកន្លែស្លដែក ឬសន្លុងស្លដែក។ ជនជាតិកួយដែលមានចំណេះដឹងខាងស្លដែកបានអនុវត្តជំនាញ និងចំណេះដឹងមន្តអាគមដើម្បីផលិតដែកពិសេសនេះបានសម្រាប់ប្រើប្រាស់។ |
| **ត្របុាំខ អែល ភា**  | ត្រពាំងចាប់ត្រី | Natural pong for fishing | ជនជាតិកួយ កំណត់ និងរក្សាត្រពាំងដែលមានត្រីច្រើនទុក ដល់ពេលទឹករីងអស់ នៅទឹកតិចពេលនោះពួកគាត់ចុះបាចទឹកចេញរួចចាប់ត្រីក្នុងត្រពាំងតែម្ដង។ |
| **តួម អ្លួម**  | វិចអន្សម | Make Nom Ansom (sticky rice cake) | សំដៅដល់សកម្មភាពនៃការវេចអក្សមដែលជនជាតិកួយវេចអក្សមជ្រូក អក្សរក្បុង អន្សមចេក អក្សមគម ឬអក្សមត្នោតនៅក្នុងកម្មវិធីបុណ្យភូមិ កម្មវិធីឡើងអ្នកតា កម្មវិធីអាពាហ៍ពិពាហ៍ ឬកម្មវិធីសែនព្រេនជាដើម។ |
| **តាក់ ញ៉ូក សណ្ដារ**  | បេះម្ជូរសណ្ដាន់ | Pick up Sandan (for sour soup) | ពាក្យនេះសំដៅលើជនជាតិកួយតែងតែបេះផ្លែសណ្ដាន់នៅពេលពួកគេមានកម្មវិធីប្រពៃណី។ |

## អក្សរ ប

| | | | |
|---|---|---|---|
| **ប៉ុម ប៉ក ក្រាស**<br> | បំពក់កង្ហែន | Use smoke to catch Kanghen (striped squirrel) | ពាក្យនេះ សំដៅលើសកម្មភាពដែលបុរសជាជនជាតិកួយជាប្រពៃណី តែងតែនាំគ្នីគ្នាទៅរកកង្ហែនតាមព្រៃ ឬតាមវាល ក្រោយពីភ្លៀងធ្លាក់មួយមេរ ដោយពួកគាត់ប្រើប្រាស់ចំណេះដឹងដើម្បីបានសត្វកង្ហែនយកទៅធ្វើជាអាហារ ហើយពួកគាត់បានចែករំលែកគ្នាបរិភោគតាមផ្ទះផងដែរ។ |
| **ប៊ិច ប្រ៉ែល ត្កត**<br>*(តំបន់អ្រើ)*<br>**ប៊ិច ប្រ៉ៀល ត្កត**<br>*(តំបន់អ្វ័)*<br> | ជីកពងត្រកួត | Dig for monitor lizard eggs | ពាក្យនេះ សំដៅលើសកម្មភាពដែលជនជាតិកួយ (បុរសពេញវ័យ) ប្រើប្រាស់ចំណេះដឹងប្រពៃណីក្នុងការរកសត្វព្រៃ។ បុរសជាជនជាតិកួយដែលមានការយល់ដឹងពីប្រពៃណីសត្វត្រកួត និងការបន្តពូជរបស់សត្វនេះ ហើយជីករកពងត្រកួតដែលមាននៅក្នុងព្រៃដើម្បីយកទៅម្ហូប។ |
| **ប៊ឺរ ចែក**<br> | រកថ្នាំ ឬរកឪសថបូរាណ | Find traditional medicine | ពាក្យនេះ សំដៅលើសកម្មភាពដែលជនជាតិកួយប្រើប្រាស់ដូចជា៖ ១/មនុស្សប្រុសរកថ្នាំឈើព្យាបាលរោគក្នុងខ្លួន (នៅពេលដែលត្រូវអំពើគេ) ។ ២/រកថ្នាំឈើព្យាលរោគប្រចាំកាយស្ងោផឹក ត្រាំងូត (នៅពេលហើមជើង ហើមដៃ ឬអាការៈផ្សេងៗទៀត)។ ៣/មនុស្សស្រីរកថ្នាំសម្រាប់ព្យាបាលដល់ស្ត្រីដែលមានបញ្ហាសុខភាពតាមផ្លូវរាងកាយ ឬសុខភាពស្ត្រី។ |
| **បុក ត្វូត ភ្លូខ** | ដកចាហួយ | Pick up Jahuoy (pink flowers) | ពាក្យនេះ៖ សំដៅដល់សកម្មភាព ដែលជនជាតិកួយ (ប្រុស ស្រី) នៅក្នុងភូមិ |

| | | | |
|---|---|---|---|
|  | | | មួយ បាននាំគ្នីគ្នាចូលព្រៃដកចាហួយ ដែលជាបន្លែព្រៃ ដែលមានដុះនៅក្នុងតំបន់ព្រៃរបោះ ឬព្រៃស្រាងនៅចន្លោះខែមេសាទៅខែមិថុនា។ ពួកគាត់ទៅរកបន្លែព្រៃជាក្រុម ជាពិសេសស្ត្រីពាក់ព័ន្ធក្នុងសកម្មភាពនេះដើម្បីបានបន្លែយកទៅបរិភោគ ដែលជាបន្លែព្រៃនេះជាបន្លែឧសថ។ |
| **ប៉ាច់ ល្អាខ**<br> | កាប់ឈើភ្លើង | harvest Chhoeu Plerng (a kind of tree) for medicinal purposes | ពាក្យនេះ សំដៅលើសកម្មភាព ដែលក្រុមបុរសៗជនជាតិកួយធ្លាប់បបួលគ្នីគ្នាចូលព្រៃដើម្បីទៅកាប់ដើមឈើភ្លើងយកទៅដំឲ្យហ្មត់ រួចហើយអូសនឹងទឹកធ្វើឲ្យទឹកនោះ មានសារជាតិពុលដែលត្រីក្នុងទឹកពុល អណ្តែតឡើង បន្ទាប់មកក្រុមមនុស្សក៏មានភាពងាយស្រួលក្នុងការត្រេងយក ឬវាយត្រីនឹងរំពាត់ដៃ ឬស្បៀជាដើម។ |
| **ចី/ចេក/ធាក់ចៀខ**<br> | ហ្មទាក់យកដំរី | Elephant keeper | ពាក្យនេះ សំដៅលើបុរសជនជាតិកួយដែលមានភាពប៉ិនប្រាសព្វក្នុងការទាក់ដំរី ជាពិសេសហ្មដំរីដែលមានចំណេះដឹងខាងមើលថៃរក្សា និងឃ្វាលដំរីគាត់ចេះវិធីទាក់ដំរីបាន។ |
| **ប៉ាច់ ត្នាយ**<br>**ប៉ាច់ ស្ងួម** | ការកាប់ចុងផ្តៅ ឬចុងសោម | Trimming off the end of rattan vine | ពាក្យនេះគេប្រើលើគោលបំណងគឺៈ នៅពេលជនជាតិកួយ ភាគច្រើនបុរសៗ (ភាគតិចជាស្ត្រី) ចូលព្រៃជ្រៅដើម្បីរកចុងសោម និងកាប់ចុងសោមយកទៅធ្វើជាម្ហូបអាហារ ដែលភាគ |

| | | | |
|---|---|---|---|
|  | | | ច្រើនគឺពួកគាត់ទៅកាប់ជាក្រុមដោយប្រើសមត្ថភាព ក្នុងការទាញយកផលពីចុងសោម។ ពួកគាត់យកទៅធ្វើជាអាហារសោមគ្គី ឬអាហារក្នុងគ្រួសារក្នុងពេលមានកម្មវិធីប្រពៃណីរបស់សហគមន៍។ ពួកគាត់យលថា វាជាអាហារឧសថ ដែលជួយដល់សុខភាពរបស់ពួកគេ ហើយជួយដល់ពួកគេមានការទំនាក់ទំនងល្អ និងការផ្ទេរចំណេះដឹងតៗដល់កូនចៅ។ |
| **ម៉ិច ភួត**  | ជីកកង្កែប | Dig for frogs | ពាក្យនេះ ត្រូវបានប្រើប្រាស់ក្នុងពេលដែលជនជាតិកួយ ជាពិសសេស្រីៗបបួលគ្នាទៅជីកកង្កែបនៅតាមមាត់អូរ ឬប្រឡាយជាពិសេសនៅរដូវវស្សានៅពេលលែលសត្វកកង្កែបទៅរស់នៅកប់ខ្លួនក្នុងដី ពួកគេជីកបានយកទៅធ្វើជាផ្អក ឬហាលទុកជាស្បៀងសម្រាប់ការងារពេលបង្កបង្កើនផល ពេលខ្លះពួកគេបានចែកចាយគ្នាហូបក្នុងភូមិ។ |
| **ប៊ឺរ ឡោម**  | ដើររកអណ្តើក | Find turtles | ពាក្យនេះ ជនជាតិកួយប្រើប្រាស់នៅរដូវប្រាំងនៅពេលដែលភ្លើងឆេះព្រៃ ជនជាតិកួយប្រើប្រាស់ចំណេះដឹងក្នុងរកអណ្តើក ដោយសារតែអណ្តើកលាក់ខ្លួនដើម្បីរក្សាសុវត្ថិភាពពីភ្លើងឆេះព្រៃ និងសត្វផ្សេងៗទៀតដែលយកពួកវាជាអាហារ។ សត្វអណ្តើកមានទំនៀមទម្លាប់របស់ពួកវានៅរដូវណាដែលត្រូវពង និងការរក្សាពងក្នុងរដូវដែលគេចខ្លួចពីភ្លើងឆេះព្រៃ។ ផ្អែកលើស្ថានភាពនេះ |

ជនជាតិកួយដែលមានការយល់ដឹងគឺពួកគាត់ត្រូវដឹងពីរបៀបក្នុងការរកសត្វអណ្តើក នៅពេលពួកគេបានអណ្តើកគឺគេយកទៅចិញ្ចឹមនៅភូមិដើម្បីត្រៀមលក់ និងទុកសម្រាប់បរិភោគតាមបែបប្រពៃណីពីបុរាណ។ ពួកគាត់យកអណ្តើកធ្វើជាអាហារសម្លកកូរជាមួយនឹងបន្លែព្រៃក្នុងកម្មវិធីបុណ្យភូមិ និងកម្មវិធីផ្សេងៗទៀតដែលរៀបចំឡើងដោយចាស់ទុំ។

**ប៉ឺរ ម្យូល**

ដើររកពង្រូល

Find pangolins



ពាក្យនេះ ជាប្រពៃណីត្រូវបានជនជាតិកួយប្រើប្រាស់ក្នុងពេលដែលពួកគេបបួលគ្នីគ្នាទៅដេកព្រៃចាប់ពីកន្លះខែចុះក្រោមជាមួយនឹងស្បៀងអាហារ។ ពួកគេទៅព្រៃអមដោយសត្វឆ្កែ និងសំភារៈជាមួយដោយប្រើប្រាស់ចំណេះដឹងពីរបៀបដែលសត្វពង្រូលលាក់ខ្លួនរស់នៅ និងពេលដែលសត្វពង្រូលចេញរកស៊ី។ ដើម្បីចាប់ពង្រូលបានជនជាតិកួយដែលជាមេក្រុមមានចំណេះដឹងត្រូវនិយាយឧបកិច្ចដើម្បីឲ្យបានសត្វពង្រូល។ នៅពេលបានពង្រូលគឺពួកគេត្រូវយកសាច់ចែកគ្នា និងធ្វើជាអាហារដោយចែកចាយបងប្អូនក្នុងភូមិ។ ការចាប់ពង្រូលគឺត្រូវប្រើប្រាស់ឧបករណ៍អង្គប់ធ្វើពីឫស្សីជាមួយនឹងវិធីសាស្ត្រដែលអាចចាប់បាន។

| | | | |
|---|---|---|---|
| **ប៊ឹរ ប៊ិច ចាំខ**<br> | ដើរជីកទំពាំង | Dig for bamboo shoots | ពាក្យនេះ ត្រូវបានជនជាតិកួយ (ស្ត្រី) តែងតែបបួលគ្នីគ្នាជាក្រុមទៅជីកទំពាំងនៅតាមព្រៃឬស្សី ឬស្សីនៅតាមមាត់ស្ទឹង មាត់អូរ មាត់ប្រឡាយ ដើម្បីយកទៅធ្វើម្ហូបអាហារដូចជា: ឆា ស្ល ប្រហើរ ស្លម្ជូរ ឬត្រាំជាទំពាំងជូរដើម្បីទុកបរិភោគនៅរដូវប្រាំង។ ក្រៅពីនេះ ពួកគាត់អាចលក់ទំពាំងបានថវិកាសម្រាប់ទិញសំភារៈកសិកម្ម ឬទិញគ្រឿងទេស។ |
| **ប៊ើក កោះ**<br>*(តំបន់អ្រើ)*<br>**ប៉ក កោះ**<br>*(តំបន់អ្វ័)*<br> | ដើរព្រៃ | Go into the forest | ជាពាក្យដែលជនជាតិកួយប្រើក្នុងពេលសកម្មភាពទៅព្រៃដោយមានគ្នីគ្នាច្រើននាក់ មានទៅដោយសំភារៈដូចជា: អង្ករ ម្ហូប កាំបិត ពូថៅ ផ្កាក ។ល។ ដើម្បីដេកព្រៃច្រើនយប់នៅតាមព្រំប្រពៃណី និងនៅតាមតំបន់ដែលមានសត្វព្រៃ។ ពួកគាត់ក៏មានសត្វឆ្កែជាច្រើនក្បាលទៅជាមួយផងដែរ ដើម្បីសុវត្ថិភាពក្នុងព្រៃ។ នៅពេលពួកគាត់បានសត្វ ពួកគាត់មកភូមិវិញចែកចាយសាច់សត្វព្រៃជូនទៅបងប្អូនក្នុងភូមិធ្វើជាអាហារ និងមានកម្មវិធីហូប ផឹកស៊ីជុំគ្នាដោយសេនព្រេនចងអំបោះតាមដៃ (ជូរ៉ាយ) ហៅព្រលឹងវិញ្ញាណមកផ្ទះវិញ។ |
| **ប៊ឹរ លៀខ**<br> | រកគ្រំ ឬស្រវាគ្រំ | Find or feel for black mussels | ពាក្យនេះ ជាប្រពៃណីជនជាតិកួយប្រើនៅពេលដែលពួកគាត់បបួលគ្នីគ្នាទៅស្រវ៉ាគ្រំនៅតាមស្ទឹងដែលមានទឹករាក់ៗ។ ពួកគាត់ទៅដោយមានគ្នាច្រើននាក់ ដោយសារតែវាមានចម្ងាយពីភូ |

| | | | |
|---|---|---|---|
| | | | មិ។ ជាទូទៅពួកគាត់ចំណាយពេលពីរថ្ងៃដើម្បីបានគ្រំយកទៅធ្វើម្ហូបអាហារ។ ជាធម្មតាពួកគាត់ចែកចាយដល់សាចញាតិនៅក្បែផ្ទះបានហូបផងដែរ ប្រសិនបើគ្រួសារណាមួយមិនអាចទៅជាមួយបាន។ |
| ប៊ូល ប្រណាក  | បូលប្រណាក | Bol Pranak (a superstitious act of the local people to foresee something) | ពាក្យនេះ សំដៅលើសកម្មភាពគ្រូមើលគ្រូព្យាបាលជាបង់បត់។ ជាទូទៅស្ត្រីជនជាតិកួយដែលមានតួនាទីខាងកាន់រូប និងស្នងរូបជាអ្នកតាំងជំនឿ។ ពេលដែលកូនក្មេង ឬមនុស្សចាស់ឈឺថ្កាត់ខុសប្រក្រី គ្រូរូបត្រូវបានគេស្នើឲ្យបូលប្រណាក ដើម្បីរកខុសត្រូវ ឬបញ្ហាជាមួយដូនតា ឬខ្មោចក្នុងដី។ |
| ប៊ូល ហ្ម្រែល ហ្ម្រួ យ  | បូលដាក់ពង់មាន់ | Chanting with Chicken egg to foresee something through his superstition | ពាក្យនេះ ជនជាតិកួយ (ស្ត្រី) ប្រើប្រាស់ក្នុងកម្មវិធីបូលប្រណាកនៅពេលដែលនរណាម្នាក់មានជម្ងឺខុសពីធម្មតា ក្មេងយំមិនបាត់ ឬប្រផ្នូលមិនល្អជាដើម។ ស្ត្រីដែលតាំងរូបត្រូវបានគេរកឲ្យមើលតាមវិធីប្រពៃណីនៃការបូល។ គេអាចបូលពងមាន់ ឬបូលប្រណាក់ដោយមានដាក់អង្ករ ឬសំភារៈផ្សេងៗទៀត ហើយមានជាសំនួរ និងចម្លើយខ្លួនេងដោយប្រើញាណ។ |
| បិន ពៀរ ស្រ | បុណ្យផ្កាស្រូវ | Paddy rice festival | ពាក្យនេះសំដៅលើពិធីបុណ្យមួយដែលជនជាតិកួយ ជាប្រពៃណីតែងតែធ្វើប្រចាំឆ្នាំ ក្រោយពីការប្រមូលភោគ |

| | | | |
|---|---|---|---|
|  | | | ផលស្រូវស្រែ និងស្រូវចម្ការ។ ពិធីបុណ្យនេះជនជាតិកួយតែងតែធ្វើនៅរដូវមាឃធំ ឬនៅតំបន់ខ្លះនៃជនជាតិកួយហៅថា “បុណ្យមាឃផ្ការចារ” ដែលបុណ្យនេះជាកាតព្វកិច្ចរបស់សមាជិកគ្រប់រូបចូលរួមរហូតដល់ចប់កម្មវិធី។ |
| **បុក សយ អ្រូក់**  | ដកតាធៀង | Pick up Ta Theang (wild vegetable) | ពាក្យនេះសំដៅដល់សកម្មភាព ដែលជនជាតិកួយនៅក្នុងភូមិណាមួយ បានបបួលគ្នីគ្នាចូលព្រៃដកបន្លែតាធៀង ដែលជាបន្លែព្រៃ។ ជាទូទៅបន្លែនេះមានដុះនៅក្នុងតំបន់ព្រៃរបោះ ឬព្រៃស្រោងនៅចន្លោះខែមេសាទៅខែមិថុនា។ ពួកគាត់ទៅរកបន្លែព្រៃជាក្រុមដើម្បីបានបន្លែព្រៃយកទៅបរិភោគ ដែលពួកគាត់យលថា បន្លែព្រៃនេះជាបន្លែឧសថ។ |
| **ចាំង លៃ**  | ទំពាំងខ្លី | Short bamboo shoot | ពាក្យនេះ ជនជាតិកួយកំពុងតែប្រើប្រាស់តិចតួច ជាមួយនឹងសកម្មភាពប្រមូលផលទំពាំងខ្លី ដោយសារតែទំពាំងខ្លីបានថយចុះខ្លាំង និងកំពុងបាត់បង់ដោយសាកត្តាការផ្លាស់ដំណាំ និងតម្រូវការរបស់កសិករ។ ខ្លីជាប្រភេទឬស្សីម្យ៉ាងដែលមានគុណប្រយោជន៍ចំពោះធម្មជាតិ មនុស្ស និងសត្វ និងអាចប្រើប្រាស់ធ្វើជាឧបករណ៍ផ្សេងៗ |
| **ចាំង ស្រង់** | ទំពាំងឬស្សី | Bamboo shoot | ពាក្យនេះ សំដៅលើទំពាំងឬស្សី ដែលជាប្រភេទបន្លែព្រៃ ដែលជនជាតិកួយ |



ភាគច្រើនស្ត្រីតែងតែអាស្រ័យផល សម្រាប់ធ្វើបន្លែហូប និងលក់បានកម្រៃ។ ជនជាតិកួយចេះពីវិធីធ្វើទំពាំងស្ងោ ទំពាំងក្រៀមទុកហូបបានយូរ ទំពាំងជ្រក់ជាដើម។

**ប៉ៀល ប្រែហ្ម តាក**



ផ្កាអង្រែដែក

Angredeak flower (wild medicinal plant

ពាក្យនេះសំដៅលើផ្កាអង្រែដែកដែលមានដុះនៅក្នុងព្រៃសហាគមន៍។ ផ្ការនេះគេអាចយកវាទៅផ្សំលាយជាមួយបន្លែផ្សេងៗទៀតក្នុងការធ្វើម្ហូប។

**ប៊ិច ត្លួត តោះ**



ជីកត្នោតព្រៃ

Dig wild palm tree

ពាក្យនេះ សំដៅលើសកម្មភាពដែលជនជាតិកួយ នាំគ្នីគ្នាដោយរេចបាយនិងម្ហូបទៅព្រៃ ដើម្បីទៅរកត្នោតព្រៃសម្រាប់យកទៅលក់បានប្រាក់កម្រៃ។

**ប៊ិ ប្រៀខ**



ជីកក្ដួច

Dig Kaduoch (a kind of wild potato)

ពាក្យនេះ សំដៅលើសកម្មភាពដែលជនជាតិកួយ (ស្ត្រី) ទៅជីកក្ដួចយកទៅកែច្នៃជាអាហារមួយបែប ដែលមានរស់ជាតិជំនួសបាយបាន។ អាហារក្ដួចត្រូវបានស្ត្រីជនជាតិកួយអនុវត្តតាមចំណេះដឹង និងវិធីមួយចំនួនដើម្បីបន្សាបវាមិនអោយមានសារធាតុពុល ហើយអាចរក្សាទុកសម្រាប់ចំអិន ឬចំហុយបរិភោគបាន។

## អក្សរ ព

| | | | |
|---|---|---|---|
| **ពួយ ក្រាស**<br> | ដេញសត្វកង្ហែន | Chase striped squirrel away | នៅពេលអាកាសធាតុស្រទំ ឬក្រោយពីភ្លៀងធ្លាក់ដើមឆ្នាំ ដោយមានស្លឹកឈើលាស់ខ្ចី តាមប្រពៃណី ជនជាតិកួយ(បុរសៗ)តែងតែបបួលគ្នីគ្នាទៅព្រៃឆ្ងាយពីភូមិ ជាមួយនឹងសត្វឆ្កែ។ ពួកគាត់បានដើរតាមគល់ឈើនិងបង្អៅឆ្កែរ។ នៅពេលមានសត្វកង្ហែនរត់ចូលរន្ធឈើ ពួកគាត់ចោះរន្ធឈើនោះដោយប្រើវិធីងាយៗ។ បើកង្ហែនចូលដំបូកពួកគាត់ត្រូវប្រើប្រាស់ចំណេះដឹងបំពក់កង្ហែន។ ក្រោយពីបានកង្ហែន ពួកគាត់យកទៅធ្វើម្ហូបហើយចែកចែកចាយគ្នា ឬបែងចែកសាច់កង្ហែនដល់គ្នាទៅវិញទៅមក។ |
| **ពួយ ត្លុខ**<br>**ពួយ ស្តេះ**<br> | ដេញចាប់សត្វស្វា | Chase monkeys | ពីបូរាណកាល នៅតាមចម្ការដែលមានម្ចាស់ច្រើននាក់ ពួកគាត់តែងតែធ្វើសកម្មភាពបណ្តេញសត្វស្វា ឬធ្វើអន្ទាក់ចាប់ស្វាដើម្បីកុំឲ្យសត្វស្វាស៊ីដំណាំក្នុងចម្ការរបស់ពួកគាត់។ ពួកគាត់មានអារម្មណ៍ថាសត្វស្វាអាចនឹងចាប់ធ្វើបាបលើក្មេងស្រីបាន ឬមនុស្សស្រីបាន បើសិនជាមានស្វាច្រើន។ ដូច្នេះបុរសៗដែលមានកម្លាំង និងមានចំណេះដឹងខាងចាប់ស្វាត្រូវតែចាប់វាដើម្បីធ្វើជាម្ហូបអាហារ។ ពេលខ្លះពួកគាត់ចាប់សត្វស្វាយកទៅចិញ្ចឹមដាក់ទ្រុង ឬចងខ្សែរដើម្បីការពារនៅផ្ទះសម្បែង និងអាចធ្វើឲ្យអ្នកក្នុងភូមិចោមរោមគ្នាទៅមើលផងដែរ។ |

| | | | |
|---|---|---|---|
| **ពួយ លីក តោះ**  | ដេញជ្រូកព្រៃ | Chase boars away | សំដៅលើសកម្មភាពរួមរបស់ជនជាតិកួយពីបុរាណ។ នៅក្នុងភូមិមួយដែលពួកគេបានបបួលគ្នីគ្នាទៅដេញជ្រូកព្រៃហ្វូង និងជ្រូកព្រៃដែលបំផ្លាញដំណាំក្នុងចម្ការ ឬដំណាំក្នុងស្រែរបស់អ្នកស្រុក។ ក្នុងការដេញជ្រូក មានព្រានព្រៃដែលមានចំណេះដឹង និងមានសមត្ថភាពក្នុងការធ្វើឲ្យបានជ្រូកព្រៃ។ ព្រានព្រៃ ត្រូវតែណែនាំដល់កូនព្រានពីរបៀបរក្សាសុត្ថិភាពជីវិត និងក្បួនដែលជ្រូកព្រៃរបួសរត់មករកមនុស្សដើម្បីវៀសនឹងចង្កូមវា កូនព្រានត្រូវដឹងពីរបៀបប្រុងប្រយ័ត្នខ្ពស់នៅពេលដែលជ្រូកមានរបួសស្នាមខ្លាំង។ |
| **ពួយ ត្យឹរ**  | ដេញឆ្មាបា | Chase flying lemur away | កាលពីបុរាណ ជនជាតិកួយប្រើពាក្យនេះ ក្នុងពេលដែលពួកគាត់មានគ្នាចាប់ពីពីរនាក់ឡើងទៅ ដើម្បីទៅរកសត្វឆ្មាបាដែលលាក់ខ្លួននៅតាមរន្ធឈើក្នុងព្រៃធំ។ ពួកគាត់ ប្រើប្រាស់វិធីសាស្ត្រប្រពៃណីដូចជាបំពក់ភ្លើងក្នុងមាត់រន្ធ គស់ប្រហោងឲ្យលឿសម្លេងខ្លាំងៗដើម្បីឲ្យវាហើរចេញមក បន្ទាប់មកពួកគាត់ប្រើវិធីសាស្ត្រចាប់យកដោយប្រុងប្រយ័ត្ន។ |
| **ព្លើ ហុខ**  | ក្បាលជាំ | Bruised head | ពាក្យនេះ សំដៅលើព្រៃដែលមានជាំ (ទឹក) ទឹកនៅក្រោម ស្មៅ និងដើមឈើដុះពីលើ ការដើរត្រូវប្រុងប្រយ័តក្រែង |

| | | | |
|---|---|---|---|
| | | | មានសត្វក្រពើនៅក្រោម ឬអាចផុងធ្លាក់ចូលទៅក្រោមបាន។ |
| **ពូច ប្រស់ ត្លូខ**<br>*(តំបន់ក្រើ)*<br>**ប៉ូច ប្រស់ត្លូខ**<br>*(តំបន់អ្វ៊ូ)*<br> | ដកប្រ៉ស់ស្វា | Pick up aromatic ginger | ពាក្យនេះ សំដៅលើសកម្មភាពដែលជនជាតិកួយ (ស្ត្រី) តែងតែនំគ្នាទៅដកស្លឹកព្រះស្វានៅតាមក្បាលស្រែ ឬតាមចម្ការចាស់ ឬនៅតាមទីតាំងដែលស្លឹកនេះលាស់ក្នុងរដូវដើមឆ្នាំ បន្ទាប់ពីមានភ្លៀងធ្លាក់ជាច្រើនមេ។ គេយកវាទៅញាំជាមួយអង្រ្កង ឬស្លក៍បាន។ |

## អក្សរ ថ

| | | | |
|---|---|---|---|
| **ថ៉ ធ្នោះ**<br>**ថ៉ ត្រើខ**<br> | ធ្វើធ្នោះ ឬធ្វើត្រើងធ្នោះ | Make thnuos (fishing equipment) | ពាក្យនេះ ត្រូវបានជនជាតិកួយប្រើប្រាស់ក្នុងសកម្មភាពធ្វើធ្នុះដើម្បីចាប់ត្រីនៅរដូវវស្សា។ ពួកគាត់ប្រើប្រាស់ចំណេះដឹងខាងធ្វើធ្នុះជាក្រុម។ មនុស្សក្នុងក្រុមនេះ គេបែងចែកការងារគ្នាធ្វើទៅតាមសមត្ថភាព រួចពួកគាត់ធ្វើការរួមគ្នា។ ទីតាំងនៃធ្នុះត្រូវធ្វើឲ្យរឹងមាំដើម្បីទប់ទប់កុំអោយទឹកវ៉ៃខ្លាំង ពីព្រោះអាចប៉ើងធ្នុសទៅតាមកម្លាំងទឹកហូរបាន។<br>ពួកគាត់អាចរកត្រីបានពីធ្នុះនេះក្នុងមួយរដូវវស្សាទឹកធំ។ |
| **ថ័ ច្លុះ បិត** | ធ្វើចន្លុះដុត | Make Chanlosh (natural torch) | ជនជាតិកួយពីបូរាណ ធ្វើចន្លុះសម្រាប់បំភ្លឺផ្ទះ ខ្ទមស្រែ ខ្ទមចម្កា និងដុតបំភ្លឺក្នុងកម្មវិធីប្រពៃណីផ្សេងៗទៀត។ ពួក |

| | | | |
|---|---|---|---|
|  | | | គាត់ធ្វើវាពីជ័រទឹកលាយជាមួយស្លឹកព្រាល ឬសំបកផ្សេងៗទៀត។ ការទៅរកស្លឹកព្រាលធ្វើចន្លុះពួកគាត់ត្រូវទៅគ្នាច្រើនដើម្បីសុវត្ថិភាពក្នុងការធ្វើដំណើរ។ |
| **ថ័ អ្គឹប ពឹត**  | ធ្វើអង្គប់ធំ | Make big traps | សំដៅដល់សកម្មភាពពីបុរាណដែលជនជាតិកួយធ្វើអង្គប់ដៃ ឬអង្គប់ធំដើម្បីបានសត្វជាអាហារ។ ជនជាតិកួយប្រើប្រាស់ចំណេះដឹងក្នុងការធ្វើអង្គប់ដោយប្រើប្រាស់កូនឈើក្នុងព្រៃ និងការបួងសួង ឬកូកព្រៃទៅដល់អារក្សព្រៃដើម្បីសុំសត្វព្រៃ នៅពេលដែលពួកគាត់បានសត្វព្រៃ ពួកគាត់បានយកសាច់សត្វទៅចែកគ្នាធ្វើជាអាហារ និងមួយចំណែកពួកគាត់ដុត ឬអាំងហូបក្លែមរួមគ្នា និងមានកកម្មវិធីរាំកំសាន្តជាមួយគ្នា។ |
| **ថ៉ាច ក្រៀល ត្រខ**  | កាយពងត្រង | Find iguana eggs | ពាក្យនេះ សំដៅលើសកម្មភាពដែលជនជាតិកួយ ជាពិសេសបុរសមានចំណេះដឹងពីការកាយរកពងត្រង។ |
| **ថ័ អ្គាប់ កោះ** | ធ្វើរង្គប់យកសត្វ | Make traps for animals hunting | ពាក្យនេះសំដៅលើសកម្មភាពពីបុរាណ ដែលជនជាតិកួយ ជាទូទៅរសនៅក្បែព្រៃ តែងតែនាំគ្នាជាក្រុមទៅធ្វើរង្គប់នៅមាត់ព្រៃ ឬព្រៃជ្រៅដើម្បីយកសត្វតាមប្រភេទផ្សេងៗយកទៅធ្វើជាអាហារតាមប្រពៃណី។ ដោយសារតែ |

| | | | |
|---|---|---|---|
| | | | នៅក្នុងព្រៃធំ ឬព្រៃជ្រៅគឺសម្បូរទៅដោយសត្វច្រើន និងសត្វសាហាវផងដែរ ដូច្នេះ ព្រានព្រៃតែងតែប្រើមន្តអាគមដើម្បីឧបកិច្ចជាមួយអ្នកតាម្ចាស់ព្រៃ គឺសុំឲ្យបានសត្វ និងកុំឲ្យមានគ្រោះថ្នាក់ដល់មនុស្សក្នុងក្រុម ហើយពេលបរិភោគសាចជាអាហារសុំឲ្យអ្នកស្រុកមានសេចក្ដីសុខ ចំរុងចំរើន។ |

## អក្សរ ស

| | | | |
|---|---|---|---|
| **សេន កន ចៅ**  | សែនកូនចៅ | | ពាក្យនេះ សំដៅលើពិធីដែលជនជាតិកួយធ្វើការសែនព្រេនដល់កូនចៅនៅពេលដែលស្ត្រី ឬបុរសស្រឡាញ់គ្នា ឬពួកគេទាំងពីរនាក់បានធ្វើអ្វីមួយជាការខុសឆ្គងប្រពៃណី ដោយក្រែងខុសនឹងដូនតា ចាស់ទុំត្រូវរៀបចំសែនព្រេន។ |
| **សេន ភ្មូច**  | សែនផ្ដាច់ខ្មោច | Ritual of expelling evil spirits | ពាក្យនេះប្រើសំដៅលើគ្រួសារដែលមានសមាជិកស្លាប់ គឺគេហៅបងប្អូនសាច់បង្កើត ឬសាច់ថ្លៃមកអង្គុយតម្រៀបគ្នាជាជួរ រួចឲ្យកាន់សំភារៈណាមួយ ហើយពោលពាក្យតាមចាស់ព្រឹទ្ធាចារ្យក្នុងភូមិ ដោយនិយាយតាមគាត់ក្នុងការពោលពាក្យសុំខមាទោស និងសុំអហោសិកម្ម កុំឲ្យវិលវល់ និងសុំឲ្យទៅបានសុខកន្លែងភពថ្មី។ |
| **សោះ ចួស យ៉ាក់** | ឡើងអ្នកតា | To get together and pray for something | ពាក្យនេះសំដៅលើ សកម្មភាពដែលជនជាតិកួយទូទាំងសហគមន៍បានព្រមព្រៀងគ្នាប្រារព្ធពិធីឡើងដូនតា ឬ |



អ្នកតាចាស់ស្រុកជាប្រចាំឆ្នាំ ដើម្បីលាបំណន់ ថ្វាយអាហារទាំងបី និង បួងសួងសុំសេចក្ដីសុខឆ្នាំថ្មី។

**សេន ជួស យ៉ាក់** សែនជូនតា Hold an ancestral spirit ceremony



ពាក្យនេះប្រើសំដៅលើ សកម្មភាពរបស់ជនជាតិកួយធ្វើពិធីសែនព្រេន នៅពេលដែល មានគ្រួសារថ្មីឡើងផ្ទះ បង្កក់សេរី បង្កក់កូន ឬលាបំណន់ជាដើម ដើម្បីសុំសេចក្ដីសុខ សេចក្ដីចំរើន។

**ស្រាក់ ក្ល** រាវខ្យង



ពាក្យនេះសំដៅលើសកម្មភាពដែលជនជាតិកួយជាពិសេសក្មេងៗ ឬស្ត្រីៗ តែងតែរាវខ្យងនៅតាមស្រែ នៅរដូវវស្សានៅតាមស្រែដែលមិនទាន់ភ្ជួរ ឬស្រែដែលភ្ជួរត្រៀមស្ទូង ដើម្បីកុំអោយខ្យងកាត់សន្ទូង និងដើម្បីយកខ្យងធ្វើជាម្ហូបអាហារ។

Hunt snails

## អក្សរ អ

**អារ់ ល័ខ** អារឈើ Saw/cut the wood



ពាក្យនេះសំដៅលើសកម្មភាពជនជាតិកួយ ជាពិសេសក្រុមបុរសដែលមានចំណេះដឹងខាងគ្រឿងឈើ ចំណេះដឹងខាងជាងឈើ និងស្គាល់ពីប្រភេទឈើព្រមទាំងស្គាល់ទីតាំងដែលមានដើមឈើសម្រាប់ទៅអារ។ ការងារអារឈើតម្រូវឲ្យមានគ្នាជាក្រុមដើម្បីមានសមត្ថភាព ឬលទ្ធភាពទាញយកគ្រឿង

| | | | |
|---|---|---|---|
| | | | ឈើបាន ពួកគាត់ជួយគ្នាក្នុងការអារឈើ និងប្រើប្រាស់ការបង្កើតគំនិតថ្មី។ |
| **អែល យ៉ាក់ គឺ**<br> | យកទល់ | Keep it from falling | ពាក្យនេះ សំដៅលើសកម្មភាពរបស់ស្ត្រីជនជាតិកួយដែលតែងតែទៅកាប់ទាល់ដែលមានដុះតាមព្រៃ ក្នុងគោលបំណងយកទៅស្លប្រហើរ ឬចំអិនអាហារសម្រាប់ការចិញ្ចឹមជ្រូកស្រុក។ |
| **អែល តី ច្រូត ស្រ**<br> | ច្រូតស្រូវយកដៃគ្នា | Mutual aid harvesting | សំដៅដល់សកម្មភាព ដែលជនជាតិកួយក្នុងភូមិណាមួយបានព្រមព្រៀងគ្នាក្នុងការច្រូតស្រូវស្រែ ឬស្រូវចម្ការរួមគ្នា ជួយគ្នាដោយមិនប្រើប្រាស់ថ្លៃឈ្នួល ដែលមានអត្ថប្រយោជន៍ប្រមូលផលស្រូវឆាប់ហើយ ឬផ្តល់ជាកម្លាំងចិត្តដល់គ្នា រក្សាបានសាមគ្គីភាព ធ្វើឲ្យពួកគាត់មានភាពក្លាហាន។ |
| **អែល ខៀល**<br> | យកឃ្មុំ | Harvest honey from bees | ពាក្យនេះសំដៅលើ សកម្មភាពជនជាតិកួយដែលរស់នៅក្បែរព្រៃធំ និងក្បែរព្រៃភ្នំ។ ជាប្រពៃណី បុរសៗដែលមានចំណេះដឹង និងជំនាញក្នុងការយកឃ្មុំលើដើមឈើធំៗ ពួកគាត់ត្រូវបែងចែកមនុស្សក្នុងក្រុមដើម្បីយកឃ្មុំបាន។ ក្រោយពីយកឃ្មុំបាន ពួកគាត់ធ្វើការបែងចែកផលប្រយោជន៍ដល់គ្នា។ មួយផ្នែកទៀតពួកគាត់ដាក់ជារបស់រួមនៅពេលលក់បានលុយគឺពួកគាត់បែងចែកកម្រៃស្មើៗគ្នា។ ក្រៅពីនេះពួកគាត់ចាត់ចែងកូនឃ្មុំជាអាហារ ទឹកឃ្មុំសម្រាប់បរិភោគឬលក់ ព្រមទាំងយក |

| | | | |
|---|---|---|---|
| | | | ក្រមូនឃុំទៅចម្រាញ់ដើម្បីប្រើប្រាស់ជាមធ្យោបាយផ្សេងៗទៀតក្នុងកម្មវិធីប្រពៃណី។ |
| **អែល ហាខ**  | យកឱម៉ាល | Obtain larvae from a wasp nest | ពាក្យនេះសំដៅលើ សកម្មភាពក្រុមបុរសជនជាតិកួយ បាននាំគ្នីគ្នាទៅយកឪម៉ាលតាមវាល ឬតាមព្រៃរបោះ។ ពួកគាត់ប្រើប្រាស់ចំណេះដឹងខ្ពស់ក្នុងការយក ដោយសារវាជាសត្វមានទ្រនិចនិងពឹសខ្លាំង។ ពួកគាត់ដុតជាមួយស្លឹកបំពក់ពីខាងក្រោមឲ្យមានផ្សែង រួចហើយពួគកាត់ឡើងកាត់សំបុកទំលាក់ចុះក្រោម ហើយយកកូនឬពងឪម៉ាលដែលនៅតាមក្រាសនៃសំបុក។ ពួកគាត់យកកូនឬពងវាធ្វើជាអាហារផ្សំជាមួយគ្រឿងទេសផ្សេងៗទៀតបង្កើតបាននូវរស់ជាតិឆ្ងាញ់។ |
| **អែល ចាំខ ស្រខ/ ចាំខលៃ**  | យកទំពាំងឬស្សី ឬទំពាំងខ្លី | Harvest bamboo shoots | ពាក្យនេះសំដៅសកម្មភាពដែលជនជាតិកួយ ទាំងស្ត្រី និងបុរសនាំគ្នាទៅកាច់ទំពាំងដែលមានដុះនៅតាមដងអូរតាមស្ទឹង ឬតាមប្រឡាយ ដើម្បីយកទៅធ្វើជាបន្លែដែលអាចហូបបានភ្លាមៗ ឬទុកហូបបានយូ ឬអាចទុកលក់បានជាប្រាក់ចំណូល។ |

**សមាសភាពសិក្សាស្រាវជ្រាវ**

- លោក ហ៊ីង ប៊ុនណាត អ្នកដឹកនាំការស្រាវជ្រាវ
- លោក យុត យឹម ជំនួយការដឹកនាំការស្រាវជ្រាវ
- លោក លី ជី ជំនួយការសិក្សាស្រាវជ្រាវ
- លោក ឡាច ចំរើន ជំនួយការសិក្សាស្រាវជ្រាវ

**សមាសភាពចូលរួមផ្តល់យោបល់ និងខ្លឹមសារអត្ថបទ**

- លោកពូ រស់ លីម អ្នកដឹកនាំសហគមន៍កួយ ភូមិបង្កើនផល
- លោក ទន់ មាន អ្នកដឹកនាំសហគមន៍កួយ ភូមិត្រពាំងទន្ទឹម
- លោកពូ អ៊ុន វី អ្នកដឹកនាំសហគមន៍កួយ ភូមិរំចេក
- លោកអ៊ុំ ហ៊ុត សារី ចាស់ស្រុកនៅសហគមន៍កួយ ភូមិក្រាំងដូង
- លោកអ៊ុំ ទុយ ឆេង ចាស់ស្រុកនៅសហគមន៍កួយ ភូមិរំដេង

**តំណាងសហគមន៍ដែលបានចូលរួមផ្តល់យោបល់**

- តំណាងសហគមន៍កួយ ភូមិភ្វាក់រលឹក
- តំណាងសហគមន៍កួយ ភូមិធ្នា
- តំណាងសហគមន៍កួយ ភូមិសំរោង
- តំណាងសហគមន៍កួយ ភូមិតស៊ូ
- តំណាងសហគមន៍កួយ ភូមិប្រើសក្អក
- តំណាងសហគមន៍កួយ ភូមិប្រមេរ
- តំណាងសហគមន៍កួយ ភូមិប៉ាលហាល

**ជំនួយការបកប្រែភាសាបរទេស**

- ក្រុមការងារបច្ចេកទេស ភូមិអាស៊ី (ខេត្តកំពង់ធំ)
- លោក ហ៊ីង ប៊ុនណាត

សម្របសម្រួល និងចងក្រង

- លោក ហ៊ីង ប៊ុនណាត

*សូមថ្លែងអំណរព្រះគុណ និងអរគុណចំពោះការអាន និងចាប់អារម្មណ៍!*

*សូមជូនពរ សុភាពល្អ សំណាងល្អ*

*សូមអធ្យាស្រ័យចំពោះចំណុចខ្វះខាត*